# ទីស្តីការគណៈរដ្ឋមន្ត្រី

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

### ហិរញ្ញប្បទានឥតសំណងលេខ ០២២៤-CAM

### អនុគម្រោង

### វាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា

# របាយការណ៍ស្តីពី

# ការចាប់ផ្តើមអនុវត្តគម្រោង


រៀបចំដោយ

ក្រុមហ៊ុនទីប្រឹក្សា POHL

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌



ឯកភាពដោយ

ធនាគារអភិវឌ្ឍន៍អាស៊ី

**ខែ ធ្នូ ២០១១**

## ពាក្យសរសេរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| CBA | ការវិភាគបន្ទុកចំណាយនិងផលចំណេញ |
| CLJR | ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ |
| COM | គណៈរដ្ឋមន្ត្រី |
| DAI | ក្រុមហ៊ុន Development Alternatives Incorporated |
| EA | ទីភ្នាក់ងារប្រតិបត្តិគម្រោង |
| ECOSOCC | ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) |
| GRP | គោលការណ៍ណែនាំពីការអនុវត្តបញ្ញត្តិកម្មល្អរបស់អាស៊ាន |
| GWG | ក្រុមការងារយេនឌ័រ (តាមក្រសួងនានា) |
| IA | ទីភ្នាក់ងារអនុវត្តគម្រោងមានក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងទេសចរណ៍ |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| IT | បច្ចេកវិទ្យាព័ត៌មានវិទ្យា |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MoE | ក្រសួងបរិស្ថាន |
| MoT | ក្រសួងទេសចរណ៍ |
| MoU | អនុស្សរណៈនៃការយោគយល់គ្នា |
| MSME | សហគ្រាសធុនតូចបំផុត ធុនតូចនិងធុនមធ្យម (អឹម អេស អឹម អុី) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| OBPR | ការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ (ប្រទេសអូស្ត្រាលី) |
| OBRP | ការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ (ពាក្យទូទៅសម្រាប់ OBPR, BRE, OIRA, etc.) |
| OCM | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ORIA | ក្រុមការងារអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (ក្រុមការងារអនុវត្តគម្រោង វ.ផ.ល.) |
| Q | ត្រីមាស |
| PA | ការវាយតម្លៃបឋម |

| | |
|---|---|
| PC & A | ក្រុមហ៊ុនប្រឹក្សាយោបល់ POHL Consulting & Associates |
| PED | ជំរុញពិពិធកម្មសេដ្ឋកិច្ច (កម្មវិធីជំនួយរបស់ ADB) |
| PIU | ផ្នែកអនុវត្តគម្រោង |
| PSC | គណៈកម្មាធិការនាយករបស់គម្រោង |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RIA | ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (វ.ផ.ល.) |
| RIS | ការវាយតម្លៃពេញលេញ (របាយការណ៍ស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIS))។ |
| SME | សហគ្រាសធុនតូចនិងមធ្យម |
| | |

**មាតិកា** ទំព័រ

ពាក្យសរសេរកាត់....................................................................................................២
មាតិកា....................................................................................................................៤
១ .**សេចក្តីសង្ខេប**....................................................................................................៦
២. **សេចក្តីផ្តើម**.........................................................................................................១០
២.១. ទិសដៅ.........................................................................................................១០
២.២. កត្តាជំរុញ.......................................................................................................១១
២.៣. សារតា..........................................................................................................១១
២.៤. លទ្ធផលពីគម្រោង.............................................................................................១២
៣ . **សកម្មភាពនៅដំណាក់កាលចាប់ផ្តើមនិងលទ្ធផល**...................................................១៥
៣.១. ការចូលមកបម្រើការងារជាផ្លូវការរបស់ក្រុមទីប្រឹក្សា.........................................១៥
៣.២. ការិយាល័យគម្រោង...........................................................................................១៥
៣.៣. គណៈកម្មាធិការនាយករបស់គម្រោង.....................................................................១៥
៣.៤. ទីភ្នាក់ងារអនុវត្តផ្សេងទៀតដែលពាក់ព័ន្ធនឹង វ.ផ.ល. នៅប្រទេសកម្ពុជា.........១៦
៣.៥. កិច្ចប្រជុំអំឡុងពេលនៃដំណាក់កាលចាប់ផ្តើម.....................................................១៧
៣.៦. ការបង្កើតឯកសារនានា.......................................................................................១៨
៤. **ការតាក់តែងបញ្ញត្តិកម្មនៅប្រទេសកម្ពុជា**.........................................................១៩
៤.១. ក្របខ័ណ្ឌច្បាប់.................................................................................................១៩
៤.២. ភាពខ្លាំងនិងភាពខ្សោយនៃការតាក់តែងបញ្ញត្តិកម្មនៅប្រទេសកម្ពុជា.............២១
៥. **សំណើវិធីអនុវត្ត វ.ផ.ល. សម្រាប់ប្រទេសកម្ពុជា**................................................២២
៥.១. ចំណុចទាំង៧របស់ វ.ផ.ល...................................................................................២២
៥.២. ដំណាក់កាលទាំងពីរក្នុងវិធីអនុវត្ត វ.ផ.ល.........................................................២៣
៥.៣.តើវិធីអនុវត្ត វ.ផ.ល.ត្រូវបានដាក់បញ្ចូលក្នុងរបៀបធ្វើសេចក្តីសម្រេច របស់ទីភ្នាក់ងារអនុវត្តដោយបែបណា.........................................................................២៦
៥.៤. ទិដ្ឋភាពគន្លឹះនានារបស់ វ.ផ.ល. .........................................................................២៨
៦. **រចនាសម្ព័ន្ធ និងមុខងារ**.........................................................................................២៩
៧. **ការគ្រប់គ្រងគម្រោង**............................................................................................៣៣
៧.១. សេចក្តីសង្ខេប-លំហូរគម្រោង...........................................................................៣៣
៧.២. លទ្ធផល១- ការកសាងសមត្ថភាពនៅក្នុងក្រុមអនុវត្តគម្រោង វ.ផ.ល (ORIA) និងទីភ្នាក់ងារអនុវត្តគម្រោង (IA)...........................................................................៣៤

៧.៣. លទ្ធផល២- ការគាំទ្រផែនការសកម្មភាពរបស់ទីភ្នាក់ងារអនុវត្តគម្រោង(IA)...៣៦
៧.៤. លទ្ធផល១ & ២- ទស្សនកិច្ចសិក្សានិងបណ្តុះបណ្តាលនៅបរទេស...............៣៨
៧.៥. លទ្ធផល៣- ការអភិវឌ្ឍសហគមន៍អ្នកអនុវត្ត វ.ផ.ល....................................៣៩
៧.៦. ដំណាក់កាលនៃការពង្រឹងនិងវាយតម្លៃ...................................................៤០
៨. **ផែនការសកម្មភាពយេនឌ័រ**.......................................................................................៤១
៩. **របាយការណ៍ស្តីពីការខាររដ្ឋបាល**......................................................................៤៤
១០. **ដំណើរឆ្ពោះទៅមុខ**............................................................................................... ៤៥
១០.១. កត្តាគន្លឹះសម្រាប់ភាពជោគជ័យ................................................................៤៥
១០.២. ការគាំទ្រផ្លូវច្បាប់..........................................................................................៤៦
១០.៣. ការពង្រីក......................................................................................................៤៧
១០.៤. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃហានិភ័យ...........................................៤៧

# ១. សេចក្តីសង្ខេប

របាយការណ៍នេះបង្ហាញពីផែនការសកម្មភាពដែលត្រូវបានបង្កើតឡើង ដើម្បីអនុវត្តគម្រោង វ.ផ.ល. (RIA) នៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះក៏កត់ត្រាសកម្មភាពនានាដែលបានអនុវត្ត និងលទ្ធផលមួយចំនួន ដែលសម្រេចបានក្នុងអំឡុងពេលនៃដំណាក់កាលចាប់ផ្តើមគម្រោង ចាប់តាំងពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។

គម្រោងនេះមានរយៈពេល៣០ខែ គិតចាប់ពីខែតុលា ឆ្នាំ២០១១ដល់ខែមិនា ឆ្នាំ២០១៨។ ទីភ្នាក់ងារប្រតិបត្តិគម្រោងគឺក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) នៅទីស្តីការគណៈរដ្ឋមន្ត្រី។ ទីភ្នាក់ងារត្រួតពិនិត្យគម្រោងគឺក្រុមការងារអនុវត្តគម្រោង វ.ផ.ល. (ORIA) ដែលត្រូវបានបង្កើតឡើងក្នុង ក.ស.វ.។ ទីភ្នាក់ងារអនុវត្ត (IA) រួមមានក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងទេសចរណ៍។ ក្រុមហ៊ុនប្រឹក្សាយោបល់ POHL Consultant & Associates ត្រូវបានជ្រើសរើសឲ្យជួយក្នុងការអនុវត្តគម្រោង។

ដើម្បីងាយយល់ សំណើ វ.ផ.ល. តម្រូវឲ្យមានរបាយការណ៍ស្តីពី វ.ផ.ល. សម្រាប់បង្ហាញព័ត៌មានឱ្យបានគ្រប់គ្រាន់ដល់អ្នកធ្វើសេចក្តីសម្រេច មុនចុះហត្ថលេខាលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តណាមួយ។

សំណើបញ្ញត្តិកម្មនៅក្នុងប្រទេសកម្ពុជា ធ្វើឡើងក្នុងទម្រង់ជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស។ វ.ផ.ល.ផ្តោតចម្បងទៅលើ ឥទ្ធិពលនានា (ខ្លឹមសារ) របស់សំណើបញ្ញត្តិកម្មជាជាងទម្រង់របស់វា។ តាមបែបបទ វ.ផ.ល ដែលបានស្នើឡើងគ្រប់សំណើបញ្ញត្តិកម្មទាំងអស់ ដែលមានផលប៉ះពាល់ដល់ធុរកិច្ច ត្រូវតែធ្វើការវាយតម្លៃបឋម (PA) ជាមុនសិន។ ផលប៉ះពាល់ដល់ធុរកិច្ចអាចមានដូចជាចំណាយកាតព្វកិច្ច ឬឥទ្ធិពលដល់ការប្រកួតប្រជែង។ ប្រសិនបើ PA បង្ហាញថាមានផលប៉ះពាល់ដល់ធុរកិច្ចគួរឲ្យកត់សម្គាល់ នោះនឹងតម្រូវឲ្យធ្វើការវាយតម្លៃពេញលេញ (RIS)។ ទាំង PA ទាំង RIS នឹងវាយតម្លៃផលប៉ះពាល់នានាដល់ធុរកិច្ច ដល់បុគ្គល និងដល់សហគមន៍ ដោយធ្វើការវិភាគតាមចំណុចណែនាំទាំង៧ គឺបញ្ហា ទិសដៅ ជម្រើស ផលប៉ះពាល់ ពិគ្រោះយោបល់ សន្និដ្ឋាន និងអនុវត្ត។ ចំណុចទាំង៧នេះមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយការវិភាគអាចធ្វើឡើងម្តងហើយម្តងទៀតដើម្បីឲ្យកាន់តែសុក្រឹត។
ការវិភាគមានកម្រិតសើៗនៅដំណាក់កាល PA និងស៊ីជម្រៅនៅដំណាក់កាល RIS។ នៅក្នុងប្រទេសកម្ពុជា ចំណុចសំខាន់នៃ វ.ផ.ល. គឺការពិគ្រោះយោបល់ តម្លាភាព និងសុភនិច្ឆ័យលើការវិភាគ។ វ.ផ.ល. នឹងវាយតម្លៃសមភាពយេនឌ័រផងដែរ ដោយតម្រូវឲ្យមានរបាយការណ៍ស្តីពីផលប៉ះពាល់ដល់យេនឌ័រក្នុងការវាយតម្លៃពេញលេញប្រសិនបើចាំបាច់។

ទិសដៅនៃ វ.ផ.ល. គឺកាត់បន្ថយបន្ទុកចំណាយ និងធ្វើឲ្យបរិស្ថានប្រកួតប្រជែងកាន់តែប្រសើរឡើង ដែលធ្វើឲ្យធុរកិច្ចកាន់តែមានប្រសិទ្ធផល និងប្រសិទ្ធភាព ដើម្បីជំរុញភាពប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ អត្ថប្រយោជន៍ដ៏សំខាន់មួយផ្នែកទៀតនៃ វ.ផ.ល. គឺកិច្ចដំណើរការតាក់តែងច្បាប់កាន់តែប្រសើរឡើង និងសម្រេចគោលនយោបាយដោយផ្អែកលើភស្តុតាងរឹងមាំ។

ដើម្បីឲ្យអនុគម្រោង វ.ផ.ល. ទទួលជោគជ័យក្នុងរយៈពេលវែង វាតម្រូវឲ្យមានលទ្ធផលសំខាន់ៗ ចំនួន៣ គឺៈ

- **លទ្ធផលទី១- ការកសាងសមត្ថភាពនៅ ORIA និង IA** ៖បង្កើតរចនាសម្ព័ន្ធ និងរៀបចំមន្ត្រីឲ្យបានសមស្រប បង្កើតប្រព័ន្ធត្រួតពិនិត្យ និងប្រព័ន្ធដំណើរការការងារឲ្យបានគ្រប់គ្រាន់ ដោយរួមបញ្ចូលមូលដ្ឋានទិន្នន័យ និងគេហទំព័រ រៀបចំឯកសារផ្សេងៗ ដូចជាគោលការណ៍ណែនាំបញ្ជីត្រួតពិនិត្យ និងទម្រង់នានា កសាងសមត្ថភាព តាមរយៈការបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សានៅការិយាល័យនៃការអនុវត្តបញ្ញត្តិកម្មល្អ (Best Regulatory Practice) នៅបរទេស និងធ្វើលទ្ធកម្មគ្រឿងបរិក្ខារចាំបាច់
- **លទ្ធផលទី២- ការគាំទ្រវាល់ផែនការសកម្មភាពរបស់ IA** ៖ រួមមានផែនការបញ្ញត្តិកម្ម និងសកម្មភាពបណ្តុះបណ្តាល ហើយក៏ត្រូវផ្តល់ការបណ្តុះបណ្តាលដោយអនុវត្តជាក់ស្តែង និងជួយក្នុងការធ្វើ វ.ផ.ល.។
- **លទ្ធផលទី៣- កសាងសហគមន៍អ្នកអនុវត្ត វ.ផ.ល.** ៖ផ្សព្វផ្សាយការយល់ដឹងពី វ.ផ.ល. និងបង្កើតសកម្មភាពជួយទ្រទ្រង់ដល់ចំណោមអ្នកពាក់ព័ន្ធនានា ដូចជាក្រសួង ស្ថាប័ន សហគមន៍ធុរកិច្ច ក្រុមអ្នកប្រើប្រាស់ ដៃគូអភិវឌ្ឍ និងគ្រឹះស្ថានសិក្សាជាន់ខ្ពស់

ដើម្បីសម្រេចបានលទ្ធផលទាំងនេះ គម្រោង វ.ផ.ល. ត្រូវបានបែងចែកជាបួនដំណាក់កាលគឺដំណាក់កាលចាប់ផ្តើមគម្រោង (២០១១) ដំណាក់កាលធ្វើសកម្មភាព (២០១២) ដំណាក់កាលពង្រឹង(២០១៣) និងដំណាក់កាលវាយតម្លៃ (២០១៤)។ ម៉ាទ្រីសនៃផែនការគម្រោង (ខាងក្រោម) សង្ខេបពីសកម្មភាពនានា ដែលបានគ្រោងទុកៈ

- មួយផ្នែកធំនៃលទ្ធផលទី១ និងផ្នែកខ្លះនៃលទ្ធផលទី២ មានការរីកចម្រើនក្នុង **ដំណាក់កាលចាប់ផ្តើម**
- សកម្មភាពទាំងនេះនឹងត្រូវបញ្ចប់នៅ**ដំណាក់កាលធ្វើសកម្មភាព** ពីព្រោះមានវិភាគទានយ៉ាងច្រើនពីក្រុមទីប្រឹក្សា។ សកម្មភាពបណ្តុះបណ្តាលភាគច្រើននឹងបន្តធ្វើ រួមទាំងការធ្វើទស្សនកិច្ចសិក្សា និងបណ្តុះបណ្តាលនៅបរទេស។ សកម្មភាពផ្សព្វផ្សាយពីការកែទម្រង់

បញ្ញត្តិកម្ម និងការធ្វើទំនាក់ទំនងទូលំទូលាយជាមួយអ្នកពាក់ព័ន្ធ ក៏នឹងត្រូវធ្វើឡើងដែរ។ មន្ត្រី IA នឹងទទួលបាននូវការជួយដោយផ្ទាល់ក្នុងការអនុវត្ត វ.ផ.ល.

- គម្រោងនេះនឹងឈានទៅ**ដំណាក់កាលនៃការពង្រឹង**នៅក្នុងឆ្នាំ២០១៣ នៅពេលដែលវិភាគទានរបស់ទីប្រឹក្សានឹងត្រូវកាត់បន្ថយ ហើយមន្ត្រីគម្រោងក៏មានសមត្ថភាពអាចនឹងធ្វើការដោយខ្លួនឯង។ ការផ្តោតសំខាន់ក្នុងដំណាក់កាលនេះ គឺការដោះស្រាយចំណុចខ្វះខាតដែលអាចកើតមានឡើងដោយមិន បានរំពឹងទុក និងសមត្ថភាពមន្ត្រី វ.ផ.ល. ដែលនៅមានភាពខ្វះចន្លោះ។ របាយការណ៍ប្រចាំឆ្នាំលើកដំបូងនឹងត្រូវបោះពុម្ពផ្សាយនៅដើមឆ្នាំ២០១៣
- ការរីកចម្រើនរបស់គម្រោងនឹងត្រូវបានពិនិត្យនៅចុងឆ្នាំ២០១៣ ហើយរបាយការណ៍ចុងក្រោយនឹងត្រូវបោះពុម្ពផ្សាយនៅដើមឆ្នាំ២០១៤ ដើម្បីបញ្ចប់**ដំណាក់កាលវាយតម្លៃ**។

ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជា ចំពោះគម្រោងមានសារៈសំខាន់ណាស់សម្រាប់ភាពជោគជ័យរបស់គម្រោង ដោយសារគម្រោងនេះ តម្រូវឲ្យមានកិច្ចសហប្រត្តិបត្តិការពីសំណាក់ក្រសួង និងអ្នកពាក់ព័ន្ធជាច្រើន ។ ម្យ៉ាងទៀត ការប្តេជ្ញាចិត្តធ្វើការងារពេញដៃពេញជើងរបស់មន្ត្រីមានសារៈសំខាន់ណាស់ ពីព្រោះមន្ត្រីគម្រោងមួយចំនួនធំមានភារកិច្ចផ្សេងទៀតរបស់រាជរដ្ឋាភិបាលដែលត្រូវបំពេញផងដែរ។ ភាពប្រាកដប្រជានិងនិរន្តភាពនៃគម្រោង មានសារៈសំខាន់ក្នុងការទទួលបាននូវការប្តេជ្ញាចិត្តពីមន្ត្រី។

ភាពប្រាកដប្រជាអាចធានាបាន ដោយចេញអនុក្រឹត្យឲ្យអនុវត្ត វ.ផ.ល.។ ការនេះនឹងបង្ហាញពីការបន្តនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលផងដែរ។ វាមានមធ្យោបាយជាច្រើនដើម្បីឲ្យគម្រោងបន្តទៅទៀតបាន។ ក្រសួងផ្សេងទៀតអាចនឹងត្រូវជ្រើសរើសជាក្រសួងសាកល្បងបន្ថែម ដែលជាយថាហេតុនាំឲ្យឈានដល់ការអនុវត្ត វ.ផ.ល. ទូទាំងរាជរដ្ឋាភិបាល។ ការអនុវត្ត វ.ផ.ល. អាចនឹងពង្រីកទៅដល់លិខិតបទដ្ឋានគតិយុត្តជាធរមានដែលមានស្រាប់ ដើម្បីសម្រេចការកាត់បន្ថយបន្ទុកបញ្ញត្តិកម្ម។ វិសាលភាពនៃ វ.ផ.ល. អាចនឹងពង្រីកលើសពីលិខិតបទដ្ឋានគតិយុត្តដែលប៉ះពាល់ធុរកិច្ច។ វិធានការទាំងនេះនឹងធានាថា ការផ្តួចផ្តើមកំណែទម្រង់បញ្ញត្តិកម្មរបស់រាជរដ្ឋាភិបាលនឹងបន្តទៀតបន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់។

## ម៉ាទ្រីសផែនការរបស់គម្រោង វ.ផ.ល. ក្នុងប្រទេសកម្ពុជាឆ្នាំ២០១១-២០១៤

| សកម្មភាព | ២០១១ | ២០១២ | | | | ២០១៣ | | | | ២០១៤ |
|---|---|---|---|---|---|---|---|---|---|---|
| | ត្រីមាស ៤ | ត្រីមាស ១ | ត្រីមាស ២ | ត្រីមាស ៣ | ត្រីមាស ៤ | ត្រីមាស ១ | ត្រីមាស ២ | ត្រីមាស ៣ | ត្រីមាស ៤ | ត្រីមាស ១ |
| រចនាសម្ព័ន្ធ **ORIA** ការបែងចែកមុខងារ និងភារកិច្ច | ■ | | | | | | | | | |
| ផ្ទេរលទ្ធកម្មសម្ភារៈនិងគ្រឿងបរិក្ខារ | ■ | ■ | | | | | | | | |
| រៀបចំប្រព័ន្ធការងាររបស់ **ORIA** និងរៀបចំបាយការណ៍ | ■ | ■ | | | | | | | | |
| រៀបចំទម្រង់ វ.ផ.ល. បញ្ជីត្រួតពិនិត្យ និងគោលការណ៍ណែនាំ | ■ | | | | | | | | | |
| បណ្តុះបណ្តាលស្តីពីដំណើរការងារ ដល់មន្ត្រី **ORIA** នៅនឹងកន្លែង | ■ | | | | | | | | | |
| រៀបចំសៀវភៅណែនាំស្តីពីនីតិវិធី ក្នុងនោះមានការណែនាំពីលទ្ធកម្ម | ■ | ■ | | | | | | | | |
| បោះពុម្ព សៀវភៅណែនាំស្តីពី វ.ផ.ល. | | ■ | ■ | | | | | | | |
| រៀបចំរបាយការណ៍ស្តីពីបញ្ញត្តិកម្ម ប្រចាំឆ្នាំ | | | | | | ■ | | | | ■ |
| បណ្តុះបណ្តាល វ.ផ.ល. ដល់មន្ត្រី **ORIA** និងមន្ត្រី **IA** | ■ | ■ | | | | ■ | | | | ■ |
| បណ្តុះបណ្តាល CBA ស៊ីជម្រៅ ដល់មន្ត្រី **ORIA** | | ■ | ■ | | | | | | | |
| បណ្តុះបណ្តល RIS ដល់មន្ត្រី **ORIA** និងមន្ត្រី **IA** | | ■ | ■ | ■ | ■ | ■ | ■ | ■ | | |
| រៀបចំផែនការសកម្មរបស់ **IA** | ■ | ■ | | | | | | | | |
| អនុវត្តប្រព័ន្ធវ.ផ.ល.ក្នុង**ORIA** និងក្នុង**IA** | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| សាកល្បងមូលដ្ឋានទិន្នន័យនិងគេហទំព័រ | ■ | ■ | | | | | | | | |
| ប្រតិបត្តិការរបស់មណ្ឌលព័ត៌មាន (i-Centre)និងការបណ្តុះបណ្តាល ដល់មន្ត្រី**ORIA** | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| បន្តអភិវឌ្ឍមណ្ឌលព័ត៌មាន(i-Centre)និងថែទាំ | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ការបញ្ចូលទិន្នន័យលិខិតបទដ្ឋានគតិយុត្ត ដែលមានស្រាប់និងនៅជាធរមាន(តែមួយដង) | | ■ | ■ | ■ | | | | | | |
| ពិធីសម្ពោធដាក់ឲ្យដំណើរការគម្រោងវ.ផ.ល. ជាផ្លូវការ(របាយការណ៍ស្តីពីការអនុវត្ត) | | ■ | | | | | | | | |
| សិក្ខាសាលាផ្សព្វផ្សាយនិងទស្សនពិភាក្សា | | ■ | ■ | | ■ | ■ | | | | ■ |
| ទស្សនកិច្ចសិក្សានៅបរទេសសម្រាប់ **ORIA**និង**IA** | | ■ | ■ | ■ | ■ | | | | | |
| បណ្តុះបណ្តលមន្ត្រី **ORIA**និង**IA** នៅបរទេស | | | ■ | ■ | ■ | ■ | | | | |
| ការវាយតម្លៃនិងរបាយការណ៍បញ្ចប់ | | | | | | | | | | ■ |

# ២. សេចក្តីផ្តើម

## ២.១. ទិសដៅ

របាយការណ៍នេះបង្ហាញពីផែនការសកម្មភាពដែលបង្កើតឡើង ដើម្បីអនុវត្តអនុគម្រោង វ.ផ.ល. នៅក្នុងប្រទេសកម្ពុជា។ ផែនការសកម្មភាពនេះត្រូវបានបង្កើតឡើងក្នុងអំឡុងពេលនៃដំណាក់កាលចាប់ផ្តើមគម្រោង គិតចាប់ពីថ្ងៃទី១០ ខែតុលា ដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១។ ការអនុវត្តគម្រោងមានរយៈពេល៣០ខែ គិតចាប់ពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ដល់ខែមីនា ឆ្នាំ២០១៤។ របាយការណ៍នេះក៏កត់ត្រាសកម្មភាពនានាដែលបានអនុវត្ត និងលទ្ធផលមួយចំនួនដែលបានបង្កើតឡើងក្នុងអំឡុងពេលនៃដំណាក់កាលចាប់ផ្តើមគម្រោង។

សំណើវ.ផ.ល.តម្រូវឲ្យមានរបាយការណ៍ស្តីពីវ.ផ.ល.ដើម្បីបង្ហាញដល់អ្នកធ្វើសេចក្តីសម្រេចមុនចុះហត្ថលេខាលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនោះ។ និយាយដោយខ្លី របាយការណ៍ស្តីពី វ.ផ.ល. នឹងមានការប្រៀបធៀបបន្ទុកចំណាយនិងផលចំណេញរបស់សំណើបញ្ញត្តិកម្ម ដោយបង្ហាញជម្រើសវិធានផ្សេងៗដែលអាចធ្វើឲ្យសម្រេចលទ្ធផលដូចគ្នា និងផ្តល់ឲ្យបញ្ញត្តិករធ្វើសេចក្តីសម្រេចប្រកបដោយព័ត៌មានពេញលេញ។

ដូច្នេះហើយគម្រោងនឹងកាត់បន្ថយចំណាយកាតព្វកិច្ចរបស់បញ្ញត្តិកម្ម និងធ្វើឲ្យបរិស្ថានប្រកួតប្រជែងកាន់តែប្រសើរ ធ្វើឲ្យធុរកិច្ចកាន់តែមានប្រសិទ្ធភាពនិងប្រសិទ្ធផល។ គម្រោងនេះក៏ធ្វើឲ្យមានតុល្យភាពកាន់តែប្រសើររវាងបន្ទុកចំណាយកាតព្វកិច្ចនិងហានិភ័យផ្សេងៗ ដែលសំណើបញ្ញត្តិកម្មនោះមានបំណងកាត់បន្ថយ។ លើសពីនោះទៀត គម្រោងនឹងជួយកាត់បន្ថយការជាន់គ្នានិងភាពមិនរឹងប៉ឹងក្នុងចំណោមលិខិតបទដ្ឋានគតិយុត្តទាំងឡាយ និងជំរុញឲ្យមានវិធីធ្វើគោលនយោបាយដោយផ្អែកលើភស្តុតាង។ ទាំងអស់នេះនឹងបង្កើនភាពប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ចកម្ពុជា។

អនុគម្រោង វ.ផ.ល. គឺជាផ្នែកមួយនៃកម្មវិធីជំរុញពិពិធកម្មសេដ្ឋកិច្ច (PED)។ កម្មវិធី PED នេះរួមមានការកែទម្រង់គោលនយោបាយជាបន្តបន្ទាប់ ដែលគាំទ្រដល់អាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០។ គោលបំណងនៃកម្មវិធីនេះ គឺកសាងវិស័យឯកជនឲ្យទូលំទូលាយនិងមានពិពិធភាព តាមរយៈការលើកកម្ពស់បរិយាកាសធុរកិច្ច។ ការបង្កើតយន្តការ វ.ផ.ល. អាចជាការរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធភាព។

## ២.២.កត្តាជំរុញ

នៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសមត្ថភាព ដើម្បីគាំទ្រកម្មវិធី PED ធនាគារអភិវឌ្ឍន៍អាស៊ី បានសម្រេចចុះកិច្ចសន្យាគាំទ្រអនុគម្រោង វ.ផ.ល. ជាមួយក្រុមហ៊ុនមួយចំនួន រួមមានក្រុមហ៊ុនប្រឹក្សាយោបល់ POHL Consulting & Associates និងក្រុមហ៊ុនប្រឹក្សាយោបល់ Pinto បន្ទាប់ពីដំណើរការដេញថ្លៃ។

ទីភ្នាក់ងារប្រត្តិបត្តិគម្រោង (EA) គឺក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ដែលជាអង្គភាពមួយរបស់ទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។

ទីភ្នាក់ងារត្រួតពិនិត្យគម្រោង គឺក្រុមការងារអនុវត្តគម្រោង វ.ផ.ល. (ORIA) ដែលត្រូវបានបង្កើតឡើងនៅក្នុង ECOSOCC។

ទីភ្នាក់ងារអនុវត្តគម្រោង (IA) គឺមានក្រសួងចំនួន៤ ដូចខាងក្រោម៖

- ក្រសួងពាណិជ្ជកម្ម (MoC)
- ក្រសួងបរិស្ថាន (MoE)
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (MIME)
- ក្រសួងទេសចរណ៍ (MoT)

គម្រោងនេះអាចពង្រីក ដោយបន្ថែមក្រសួងមួយ ឬពីរទៀត ប្រសិនបើក្រសួងទាំង៤ ទទួលបានជោគជ័យក្នុងការអនុវត្តគម្រោង។

## ២.៣.សារៈតារ

ក្រោមអនុកម្មវិធី PED (PED-SP1) ផ្តល់ហិរញ្ញប្បទានដោយ ADB (២១លានដុល្លាអាមេរិក) ក្នុងឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជាអនុវត្តវិធានការសម្រួលពាណិជ្ជកម្ម និងវិនិយោគជាបន្តបន្ទាប់ ដែលជាមូលដ្ឋានគ្រឹះសម្រាប់បង្កើនភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ចក្នុងរយៈពេលវែង។

អនុកម្មវិធី (PED-SP2) បង្កើតឡើងតាមរយៈកំណែទម្រង់ដែលបានអនុវត្តក្នុង PED-SP1 ដោយបង្កើនការយកចិត្តទុកដាក់លើកំណែទម្រង់បញ្ញត្តិកម្មនិងគោលនយោបាយប្រកួតប្រជែង។

កំណែទម្រង់ទាំងនេះជួយជំរុញពិពិធកម្មសេដ្ឋកិច្ចតាមរយៈ ៖

ក) បង្កើនការប្រកួតប្រជែងទីផ្សារក្នុងស្រុកនិងលើកស្ទួយប្រសិទ្ធផលបញ្ញត្តិកម្ម

ខ) ពង្រឹងទំនុកចិត្តរបស់អ្នកវិនិយោគលើបរិស្ថានបញ្ញត្តិកម្ម និងជំរុញឲ្យមានការច្នៃប្រឌិតនៅក្នុងទីផ្សារ

គ) លើកកម្ពស់សមត្ថភាពគោលនយោបាយពាណិជ្ជកម្ម និងពង្រឹងវិធានការសម្រួលពាណិជ្ជកម្មចំពោះចង្វាក់ផ្គត់ផ្គង់ទាំងមូល។

គម្រោង វ.ផ.ល. ស្ថិតនៅក្រោម (ក) និង (ខ) នៃ PED-SP2។

គម្រោងនេះបានកើតឡើងបន្ទាប់ពីមានបេសកកម្មពិនិត្យស្ថានភាពជាក់ស្តែង និងសកម្មភាពផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងតាំងពីឆ្នាំ២០០៩ ហើយឈានដល់ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និង ADB នៅខែមិថុនា ឆ្នាំ២០១០។

របាយការណ៍ថ្មីៗ ស្តីពីការធ្វើធុរកិច្ចឆ្នាំ២០១២ចេញដោយធនាគារពិភពលោក បានចាត់ថ្នាក់ប្រទេសកម្ពុជានៅលេខរៀងទី១៣៨ ក្នុងចំណោមប្រទេសចំនួន១៨៣ ចំពោះភាពងាយស្រួលធ្វើធុរកិច្ច។ ប្រទេសកម្ពុជាមានចំណាត់ថ្នាក់ក្រោមប្រទេសអាស៊ានភាគច្រើន ដូចជាប្រទេសថៃ ម៉ាឡេស៊ី វៀតណាម និងហ្វីលីពិន។ បញ្ហានេះតម្រូវឲ្យកម្ពុជាកាត់បន្ថយបន្ទុកធុរកិច្ច។ វ.ផ.ល. អាចជាមធ្យោបាយល្អមួយក្នុងការធ្វើឲ្យសម្រេចគោលបំណងនេះ។

## ២.៤.លទ្ធផលគម្រោង

ដើម្បីឲ្យអនុគម្រោងទទួលបានជោគជ័យក្នុងរយៈពេលវែង ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

- រចនាសម្ព័ន្ធនិងដំណើរការងារសមស្របរបស់ ORIA និង IA
- ការវិនិយោគកម្រិតខ្ពស់ក្នុងការបណ្តុះបណ្តាលមន្ត្រីធ្វើការនៅក្នុងគម្រោង
- សកម្មភាពផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីគម្រោង

ការបង្កើតឲ្យមាន វ.ផ.ល. ក្នុងរាជរដ្ឋាភិបាល នឹងជួយក្នុងការរៀបចំគោលនយោបាយដោយរាប់ទាំងតម្លាភាព និងការចូលរួមពីអ្នកពាក់ព័ន្ធក្នុងដំណើរការធ្វើគោលនយោបាយនេះ។

លទ្ធផលរបស់គម្រោងមាន៣សំខាន់ ៖

- ការកសាងសមត្ថភាពនៅ ORIA
- ការគាំទ្រផែនការសកម្មភាពរបស់ IA និង
- ការកសាងសហគមន៍អ្នកអនុវត្ត វ.ផ.ល.។

លទ្ធផលទាំង៣ខាងលើមានការអធិប្បាយដូចខាងក្រោម ៖

### (ក) ការកសាងសមត្ថភាពនៅ ORIA

**ក១. ផ្តល់ការគាំទ្រក្នុងការបង្កើត ORIA ដោយរាប់ទាំងការជួយ ៖**

- រៀបចំរចនាសម្ព័ន្ធ មុខងារនិងភារកិច្ច និងគុណវឌ្ឍិដែលតម្រូវឲ្យមាន

- បង្កើតរបៀបរបបធ្វើការងារផ្ទៃក្នុង ប្រព័ន្ធត្រួតពិនិត្យ និងការរៀបចំរបាយការណ៍ និង
- បង្កើតសៀវភៅណែនាំ គោលការណ៍ណែនាំ បញ្ជីត្រួតពិនិត្យ និងគំរូសម្រាប់ការវាយតម្លៃ។

**ក២. ការកសាងសមត្ថភាពមន្រ្តីនៅ ORIA ដោយផ្តល់ការបណ្តុះបណ្តាលលើ ៖**

- ដំណើរការការងារផ្ទៃក្នុង ប្រព័ន្ធត្រួតពិនិត្យ និងការរៀបចំរបាយការណ៍
- បច្ចេកទេស វ.ផ.ល. ទាក់ទងនឹងចំណុចទាំង៧ របស់ វ.ផ.ល.
- បច្ចេកទេសវិភាគបន្ទុកចំណាយនិងផលចំណេញ (CBA) និងឧបករណ៍វិភាគសេដ្ឋកិច្ចផ្សេងទៀត និង
- បណ្តុះបណ្តាលគ្រូបង្គោល (បណ្តុះបណ្តាលមន្រ្តី ORIA ឲ្យក្លាយជាអ្នកបណ្តុះបណ្តាល និងធ្វើសកម្មភាពផ្សព្វផ្សាយផ្សេងៗ)។

**ក៣. ជួយមណ្ឌលព័ត៌មាន (I-Centre) ដើម្បីបង្កើតប្រព័ន្ធព័ត៌មានវិទ្យា។ មណ្ឌលព័ត៌មានមានភារកិច្ចដូចខាងក្រោម ៖**

- សាកល្បងមូលដ្ឋានទិន្នន័យផ្ទៃក្នុង និងគេហទំព័រ
- បង្កើតគេហទំព័រ មូលដ្ឋានទិន្នន័យដែលងាយស្រួលប្រើ និងមានសុវត្ថិភាព និង
- ផ្តល់ការគាំទ្រដល់អ្នកប្រើប្រាស់មូលដ្ឋានទិន្នន័យ គេហទំព័រ កម្មវិធីកុំព្យូទ័រ និងគ្រឿងបរិក្ខារព័ត៌មានវិទ្យា។

**ក៤. របាយការណ៍ដែលតម្រូវឲ្យធ្វើ៖ ជួយ ORIA ក្នុងការរៀបចំរបាយការណ៍ការប្រចាំឆ្នាំ**

**ក៥. សកម្មភាពផ្សព្វផ្សាយ និងលើកម្ពស់ការយល់ដឹងអំពី វ.ផ.ល. ដោយធ្វើការជាមួយមន្រ្តី ORIA ដើម្បី ៖**

- ធ្វើសកម្មភាពផ្សព្វផ្សាយ និងលើកម្ពស់ការយល់ដឹង
- ជួយ IA ក្នុងការបង្កើតផែនការបញ្ញត្តិកម្ម និង
- ជួយរៀបចំកម្មវីធីទំនាក់ទំនងជាមួយការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ(OBPR) នៅបរទេស ។

**ក៦. ជួយរៀបចំការធ្វើលទ្ធកម្មគ្រឿងបរិក្ខារ**

## (ខ) ការគាំទ្រផែនការសកម្មភាព វ.ផ.ល. របស់ IA

ការងាររបស់ ORIA និង IA និងការបង្កើតផែនការសកម្មភាពដែលរួមមាន ៖

- ការបណ្តុះបណ្តាលនៅនឹងកន្លែងអំពីនីតិវិធី ការអនុវត្ត និងបច្ចេកទេស វ.ផ.ល.

- ការបណ្តុះបណ្តាលអំពីការប្រើប្រាស់ទម្រង់នៃការវាយតម្លៃ និងរៀបចំផែនការធ្វើបញ្ញត្តិកម្ម និង
- ការធ្វើលទ្ធកម្មបរិក្ខារចាំបាច់ ដើម្បី IA បំពេញការងារឲ្យមានប្រសិទ្ធភាព។

### (គ) បង្កើតសហាគមន៍អ្នកអនុវត្ត វ.ផ.ល.

លទ្ធផលនេះផ្តោតលើចំណុចសំខាន់ចំនួន២ គឺ៖

- ជួយ ORIA និងលេខាធិការដ្ឋាន SME តាមរយៈ MIME ដោយធ្វើសកម្មភាពផ្សព្វផ្សាយ វ.ផ.ល. និងការប្រតិបត្តិទម្លាប់ល្អក្នុងការតាក់តែងបញ្ញត្តិកម្ម។ ការងារនេះរួមមានការធ្វើទស្សនកិច្ចពិភាក្សា សិក្ខាសាលាផ្សព្វផ្សាយ វ.ផ.ល. ជាបន្តបន្ទាប់ជាមួយស្ថាប័នរបស់រាជរដ្ឋាភិបាល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត (អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានឧត្តមសិក្សា) ហើយនឹងផ្សព្វផ្សាយឯកសារដល់សាធារណជន
- ជួយ ORIA ដើម្បីរៀបចំឲ្យពលរដ្ឋកម្ពុជា មួយភាគធំមានជំនាញ វ.ផ.ល. ការវិភាគបន្ទុកចំណាយនិងផលចំណេញ និងឧបករណ៍វិភាគសេដ្ឋកិច្ចផ្សេងទៀត តាមរយៈសិក្ខាសាលាបណ្តុះបណ្តាល ឬទស្សនកិច្ចពិភាក្សាអំពីការប្រើប្រាស់ឧបករណ៍ វ.ផ.ល.។

លទ្ធផលទាំងនេះមានការជាន់គ្នាខ្លះ។ ឧទាហរណ៍ ការកសាងសមត្ថភាពមន្ត្រី ORIA និង IA អាចធ្វើរួមគ្នាតែម្តង។ ការនេះរួមមានមន្ត្រី RIA ដែលត្រូវបានបញ្ជូនទៅធ្វើទស្សនកិច្ចសិក្សា និងបណ្តុះបណ្តាលនៅការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ(OBPR) នៅបរទេស។ ម្យ៉ាងទៀត លទ្ធផល(ក៥) និង (គ) មានភាពស្រដៀងគ្នាច្រើន។

# ៣. សកម្មភាពនៅដំណាក់កាលចាប់ផ្តើម និងលទ្ធផល

## ៣.១. ការចូលបម្រើការងាររបស់ទីប្រឹក្សា

តារាងខាងក្រោមបង្ហាញលម្អិតអំពីរយៈពេលធ្វើការរបស់ទីប្រឹក្សានៅក្នុងគម្រោងនេះ ៖

តារាងទី១: ការចូលបម្រើការងាររបស់ទីប្រឹក្សា

| ឈ្មោះ | មុខងារ | ពេលវេលាចាប់ផ្តើមការងារ | រយៈពេលរៀបចំរបាយការណ៍អំពីការចាប់ផ្តើមគម្រោង(ខែ) | រយៈពេលនៃកិច្ចសន្យាការងារគិតជាខែ (ដាច់ៗពីគ្នា) |
|---|---|---|---|---|
| Mr. Sabesh Shivasabesan | ប្រធានក្រុមទីប្រឹក្សា-អ្នកជំនាញបញ្ញត្តិកម្មអន្តរជាតិ | ១០តុលា២០១១ | ១.៥ | ១២ |
| នឹងជ្រើសរើស | ទីប្រឹក្សា បញ្ញត្តិកម្មសេដ្ឋកិច្ចអន្តរជាតិ | រំពឹង មករា ២០១២ | 0.0 | ១២ |
| Mr. Mao Chhuon | ទីប្រឹក្សាអភិបាលគម្រោង | ១០តុលា២០១១ | ១.០ | ១៨ |
| Ms. Rothavy So | ទីប្រឹក្សាឯកទេសផ្នែកយេនឌ័រ | ១០តុលា២០១១ | ១.០ | ១២ |

## ៣.២. ការិយាល័យគម្រោង

ការិយាល័យគម្រោងស្ថិតនៅជាន់ទី៦ អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី អាសយដ្ឋានអគារលេខ៩៥ មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ។ គ្រឿងសង្ហារិមនិងគ្រឿងបរិក្ខារការិយាល័យត្រូវបានខ្ចីពីទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ដំណើរការគម្រោងចាប់ពីថ្ងៃដំបូងនៃការចាប់ផ្តើមអនុវត្តគម្រោង។ គ្រឿងបរិក្ខារ កុំព្យូទ័រ រថយន្ត និងគ្រឿងសង្ហារិម ទើបនឹងចាប់ផ្តើមធ្វើលទ្ធកម្មនៅពេលក្រុមហ៊ុនទីប្រឹក្សា POHL ចូលមកបំពេញការងារ។

ទីប្រឹក្សាគម្រោងមួយចំនួន បានចូលមកបំពេញការងារចាប់តាំងពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។ សម្ភារៈការិយាល័យមួយចំនួន ដូចជាកុំព្យូទ័រ ម៉ាស៊ីនព្រីនធ័ ម៉ាស៊ីនហ្វូតូកូពី និងម៉ាស៊ីនស្កេន តុកៅអី បណ្តាញអ៊ិនធឺណែត បានផ្តល់ដោយ ECOSOCC។

## ៣.៣. គណៈកម្មាធិការនាយករបស់គម្រោង

គណៈកម្មាធិការនាយករបស់គម្រោង (PSC) ត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យការអនុវត្តគម្រោង។ សមាសភាព PSC មានប្រធាន ECOSOCC នាយក នាយករង អ្នកគ្រប់គ្រង

គម្រោង តំណាង ADB (Mr. Kelly Bird, Principle Economist, SEPF) និងប្រធាន IA មកពីក្រសួងអនុវត្តទាំង៤ ។ ទីប្រឹក្សានឹងផ្តល់ការគាំទ្រផ្នែកលេខាធិការ និងភស្តុភារដល់ PSC។

PSC ប្រជុំយ៉ាងតិចមួយដងនៅរៀងរាល់៦ខែ ហើយមានមុខងារដូចខាងក្រោម ៖

- វាយតម្លៃការរីកចម្រើនរបស់គម្រោង ដោយរាប់ទាំងការកំណត់ពីការលំបាកនិងឧបសគ្គទាំងឡាយ និងស្នើវិធានការដោះស្រាយ
- វាយតម្លៃការងាររបស់ទីប្រឹក្សា ដោយរាប់ទាំងការធ្វើអធិប្បាយលើរបាយការណ៍សំខាន់ៗរបស់ទីប្រឹក្សា (របាយការណ៍ស្តីពីការចាប់ផ្តើមអនុវត្តគម្រោង របាយការណ៍ពាក់កណ្តាលគម្រោង និងរបាយការណ៍បញ្ចប់គម្រោង)
- ធ្វើសេចក្តីសម្រេចចំពោះការផ្លាស់ប្តូរពេលវេលា និងការចំណាយលើសកម្មភាពផ្សេងៗ និងលទ្ធផលរបស់គម្រោង។

ប្រធាន ECOSOCC ត្រូវរាយការណ៍ពីការរីកចម្រើនរបស់គម្រោង ជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

## ៣.៤. ទីភ្នាក់ងារអភិវឌ្ឍផ្សេងទៀតដែលមានការពាក់ព័ន្ធនឹង វ.ផ.ល. ក្នុងប្រទេសកម្ពុជា

ពុំសូវមានការងារ វ.ផ.ល. ជាក់លាក់ណាមួយដែលត្រូវបានធ្វើក្នុងប្រទេសកម្ពុជានៅឡើយ ក្រៅពីសកម្មភាពទាំងឡាយដែលគាំទ្រដោយ ADB ពីឆ្នាំ២០០៩។ ទោះបីជាយ៉ាងនោះក៏ដោយ ក៏មានសកម្មភាពពាក់ព័ន្ធនឹងវ.ផ.ល.មួយចំនួន ដែលអាចផ្តល់អត្ថប្រយោជន៍ដល់គម្រោងវ.ផ.ល.។

គម្រោង MSME2/BEE ដែលផ្តល់មូលនិធិដោយជំនួយអភិវឌ្ឍអន្តរជាតិរបស់សហរដ្ឋអាមេរិក (ចាត់ចែងដោយ DAI) បានរៀបចំសេចក្តីព្រាងគោលគំនិតអំពីការរៀបចំសេចក្តីព្រាងច្បាប់ដែលមានសមាសធាតុពាក់ព័ន្ធនឹង វ.ផ.ល.។ DAI ក៏បានធ្វើការងារផងដែរលើវិធានទាំងឡាយដើម្បីដាក់បញ្ញត្តិលើការផ្គត់ផ្គង់ទឹកស្អាត ដែលអាចអនុវត្ត វ.ផ.ល.។

មូលនិធិអាស៊ី (Asia Foundation) បានធ្វើការសិក្សាទៅលើបន្ទុកចំណាយធុរកិច្ច និងបោះពុម្ពបណ្ណពិន្ទុសហគ្រាសអាជីវកម្មតាមខេត្ត។

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (CLJR) សម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ឆ្នាំ២០០៣ ក្នុងនោះមានការរៀបចំសេចក្តីព្រាងច្បាប់ និងការពង្រឹងការអនុវត្តច្បាប់ដែលជាអាទិភាពនៅក្នុងយុទ្ធសាស្ត្រនេះ។ ភារកិច្ចនេះតម្រូវឲ្យមានការសម្របសម្រួលវិធីរៀបចំសេចក្តីព្រាងច្បាប់របស់ក្រសួងទទួលបន្ទុក និងប្រសិនបើចាំបាច់ មានការផ្តល់ជំនួយបច្ចេកទេស។ ក្នុងបរិបទនេះ CLJR អាចពិនិត្យមើល វ.ផ.ល. ដើម្បីពង្រឹងមូលដ្ឋានគោលនយោបាយក្នុងការតាក់តែងបញ្ញត្តិកម្ម។ ហេតុនេះ គម្រោង

នេះអាចជាថាមពលរួមជាមួយនឹងគម្រោង វ.ផ.ល. ហើយការពិភាក្សាបឋមក៏ត្រូវបានរៀបចំឡើងដែរ។

## ៣.៥. កិច្ចប្រជុំអំឡុងពេលចាប់ផ្តើមអនុវត្តគម្រោង

ក្រុមទីប្រឹក្សា (តារាងទី១ក្នុងផ្នែក ៣.១) បានជួបជាមួយប្រធាន និងសមាជិក ECOSOCC នៅថ្ងៃដំបូងនៃដំណាក់កាលចាប់ផ្តើម (ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១) ដើម្បីពិភាក្សារិះរកវិធីសាស្រ្តជំរុញគម្រោងឲ្យមានការរីកចម្រើន។

នៅសប្តាហ៍បន្តបន្ទាប់ទៀត (ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១) មានកិច្ចប្រជុំទី២។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីសំណាក់ក្រុមទីប្រឹក្សា អ្នកគ្រប់គ្រងគម្រោងពីADB អ្នកគ្រប់គ្រងគម្រោងនៃក្រុមហ៊ុន POHL Consulting & Assosiates និងមន្ត្រី IA និង ORIA ភាគច្រើន (រួមទាំងនាយកគម្រោង និងអ្នកគ្រប់គ្រងគម្រោង)។

សិក្ខាសាលាពិគ្រោះយោបល់បានរៀបចំឡើងនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១ ដើម្បីប្រមូលគំនិតយោបល់ក្នុងការធ្វើឲ្យសម្រេចគោលបំណង។ ក្រុមទីប្រឹក្សា អ្នកគ្រប់គ្រងគម្រោងនៃក្រុមហ៊ុន POHL Consulting & Assosiates មន្ត្រី ORIA និង IA បានចូលរួមក្នុងសិក្ខាសាលានេះ។ ប្រធានក្រុមទីប្រឹក្សា គឺលោក Sabesh Shivasabesan បានធ្វើបទបង្ហាញអំពីការចាប់ផ្តើមគម្រោង បន្ទាប់មក មានការធ្វើបទបង្ហាញដោយសង្ខេបអំពីបញ្ហាយេនឌ័រ ដោយទីប្រឹក្សាឯកទេសផ្នែកយេនឌ័រ គឺលោកស្រី Rothavy So អ្នកចូលរួមត្រូវបានបែងចែកជាក្រុមពិភាក្សាដើម្បីប្រមូលគំនិតយោបល់ បន្ទាប់មក តំណាងក្រុមនីមួយៗ បានបង្ហាញពីលទ្ធផលរបស់ខ្លួនដល់ក្រុមផ្សេងទៀត។ លទ្ធផលនៃក្រុមនីមួយៗ ត្រូវបានយកមកពិចារណាបញ្ចូលក្នុងយុទ្ធសាស្រ្តសម្រាប់អនុវត្តគម្រោង។

វគ្គបណ្តុះបណ្តាល៣ត្រូវបានរៀបចំឡើងក្នុងអំឡុងពេលចាប់ផ្តើម ដើម្បីឲ្យមន្ត្រី ORIA និង IA អាចអនុវត្ត វ.ផ.ល.។ វគ្គបណ្តុះបណ្តាលទាំងនេះមានប្រយោជន៍សម្រាប់មន្ត្រី ORIA និង IA ក្នុងការបញ្ចេញទស្សនៈរៀងៗខ្លួន និងឈានដល់ការឯកភាពសម្រាប់ដំណើរឆ្ពោះទៅមុខ។

ការសម្ពោធដាក់ឲ្យដំណើរការគម្រោងជាផ្លូវការ ដែលគ្រោងធ្វើឡើងក្នុងត្រីមាសទី១ នៃឆ្នាំ២០១២ ដើម្បីបង្ហាញរបាយការណ៍ស្តីពីការចាប់ផ្តើមគម្រោងដល់មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល។ ពិធីសម្ពោធនេះក៏ជាសកម្មភាពផ្សព្វផ្សាយផងដែរអំពីកំណែទម្រង់បញ្ញត្តិកម្មនៅក្នុងប្រទេសកម្ពុជា។

មានកិច្ចប្រជុំខ្លះទៀតជាមួយ IA និងអ្នកពាក់ព័ន្ធ (DAI, CJLR, IFC...) ក្នុងអំឡុងពេលចាប់ផ្តើមគម្រោង។

## ៣.៦.ការបង្កើតឯកសារផ្សេងៗ

ឯកសារមួយចំនួនត្រូវបានបង្កើតឡើង មានដូចខាងក្រោម ៖

- ទម្រង់ PA (ការវាយតម្លៃបឋម (Preliminary Assessment)
- បញ្ជីត្រួតពិនិត្យសម្រាប់ទម្រង់ PA
- គោលការណ៍ណែនាំសម្រាប់អនុវត្ត វ.ផ.ល.
- ការបែងចែកមុខងារនិងភារកិច្ច
- ការរៀបចំរចនាសម្ព័ន្ធបន្ថែម
- ផែនការបញ្ញត្តិកម្ម - IA នីមួយៗ មានរៀបចំផែនការបញ្ញត្តិកម្មរៀងៗខ្លួន ដោយផ្អែកលើទម្រង់ផែនការបញ្ញត្តិកម្ម។

ឯកសារទាំងនេះត្រូវបានបកប្រែជាភាសាខ្មែររួចហើយ។

ឯកសារទាំងនេះរំពឹងថា នឹងមានការកែប្រែនៅពេលទទួលបានបទពិសោធក្នុងដំណាក់កាលធ្វើសកម្មភាព។

# ៤. ការតាក់តែងបញ្ញត្តិកម្មនៅក្នុងប្រទេសកម្ពុជា

## ៤.១. ក្របខ័ណ្ឌច្បាប់

លិខិតូបករណ៍ជាផ្លូវការនៅក្នុងប្រទេសកម្ពុជាមានទម្រង់ជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ៖

- ច្បាប់ត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា ដែលបានយល់ស្របតាមទម្រង់ និងគតិច្បាប់ទាំងស្រុង និងប្រកាសឲ្យប្រើដោយព្រះរាជក្រម (មើលក្រាហ្វិកខាងក្រោម)
- ព្រះរាជក្រឹត្យត្រូវបានបង្កើតឡើងដោយអនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់ ដោយមានព្រះហស្តលេខាយល់ព្រមពីព្រះមហាក្សត្រ
- អនុក្រឹត្យត្រូវបង្កើតឡើងដោយអនុលោមតាមច្បាប់ ហើយយល់ព្រមដោយគណៈរដ្ឋមន្ត្រី និងចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី
- ប្រកាសត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រី អនុលោមតាមច្បាប់ ឬអនុក្រឹត្យ។ ជាទូទៅប្រកាសមិនចងភ្ជាប់នឹងក្រសួងផ្សេងៗទៀត ឬរដ្ឋាភិបាលទេ ទោះបីវាពាក់ព័ន្ធនឹងការងារសាធារណៈក៏ដោយ។

បច្ចុប្បន្ននេះ គ្រប់សំណើបញ្ញត្តិកម្មទាំងអស់ត្រូវឆ្លងកាត់ការពិនិត្យរបស់ ECOSOCC និងក្រុមប្រឹក្សាអ្នកច្បាប់ លើខ្លឹមសារគតិច្បាប់ និងទម្រង់។ អង្គភាពទាំងពីរនេះជាផ្នែករបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

រូបភាពទី១ បង្ហាញពីដំណើរការតាក់តែងច្បាប់នៅក្នុងប្រទេសកម្ពុជា។ ការតាក់តែងព្រះរាជ-ក្រឹត្យក៏មានដំណើរការប្រហាក់ប្រហែលគ្នានេះដែរ។

## រូបភាពទី១ : ដំណើរការតាក់តែងច្បាប់នៅក្នុងប្រទេសកម្ពុជា




ប្រភព: វិទ្យាស្ថានប្រជាធិបតេយ្យខ្មែរ

ក្រសួងពាក់ព័ន្ធរៀបចំសេចក្តីព្រាងអនុក្រឹត្យ (និងច្បាប់) ហើយផ្ញើសេចក្តីព្រាងទាំងនេះមកអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល។ អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាលរៀបចំកិច្ចប្រជុំចំនួន៣វគ្គផ្សេងៗគ្នា ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនិងច្បាប់របស់ក្រសួងពាក់ព័ន្ធ ៖

- ក្រសួងពាក់ព័ន្ធបង្ហាញសេចក្តីព្រាងនៅក្នុងកិច្ចប្រជុំជំនាញបច្ចេកទេស ដែលដឹកនាំដោយ ECOSOCC និងក្រុមប្រឹក្សាអ្នកច្បាប់។ ទិដ្ឋភាពសេដ្ឋកិច្ច ឬសង្គមកិច្ច ឬវប្បធម៌ និងទិដ្ឋភាពច្បាប់នៃសេចក្តីព្រាង ត្រូវបានយកមកពិភាក្សា ហើយផ្តល់អនុសាសន៍ជូនកិច្ចប្រជុំអន្តរក្រសួង
- កិច្ចប្រជុំអន្តរក្រសួងមានការចូលរួមទូលាយជាង ដោយមានតំណាងគ្រប់ក្រសួងពាក់ព័ន្ធបន្ថែមលើអ្នកចូលរួមជំនាញបច្ចេកទេស។
  - ជាទូទៅក្នុងកិច្ចប្រជុំនេះ បញ្ហាភាគច្រើនក្នុងសេចក្តីព្រាងត្រូវបានដោះស្រាយរួចរាល់ ហើយសេចក្តីព្រាងអនុក្រឹត្យនេះនឹងត្រូវដាក់ជូននាយករដ្ឋមន្ត្រីដើម្បីសម្រេច។ ចំពោះសេចក្តីព្រាងច្បាប់ត្រូវដាក់ជូនរដ្ឋសភា ដើម្បីអនុម័ត (មើលក្រាហ្វិកខាងលើ)។ សេចក្តីព្រាងខ្លះត្រូវបានវាយតម្លៃថាមិនសមស្រប។
- សេចក្តីព្រាងខ្លះសំខាន់និងបន្ទាន់ នឹងត្រូវដាក់ពិភាក្សានិងសម្រេចនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីតែម្តង ដែលដឹកនាំដោយនាយករដ្ឋមន្ត្រី។

ក្រសួងពាក់ព័ន្ធមានសិទ្ធិចេញប្រកាសដោយអនុលោមតាមច្បាប់ ព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

## ៤.២. ភាពខ្លាំង និងភាពខ្សោយនៃការវិធីតាក់តែងច្បាប់បច្ចុប្បន្ន

ដូចដែលបានបង្ហាញខាងលើ ទោះបីជាមាននីតិវិធីផ្លូវការសម្រាប់ធ្វើច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យក៏ដោយ ក៏ពុំមានការវិភាគសេដ្ឋកិច្ចជាលាយលក្ខណ៍អក្សរដែរ។ នីតិវិធីសម្រាប់ចេញប្រកាសមានលក្ខណផ្លូវការតិចតួច។ បញ្ហានេះបណ្តាលឲ្យមានការខ្វះខាតដល់ការយល់ដឹងពីបន្ទុកចំណាយតម្រូវដោយបទប្បញ្ញត្តិទាំងនោះ។ ក្នុងករណីខ្លះ សាធារណជនមិនបានដឹងពីបទប្បញ្ញត្តិដែលបានចេញនោះផង។ ការខ្វះខាតក្នុងការបែងចែកការទទួលខុសត្រូវរបស់ក្រសួងនានាឲ្យដាច់ស្រឡះ អាចនាំឲ្យមានការជាន់ភារកិច្ចគ្នា និងគ្មានសង្គតិភាព ដែលធ្វើឲ្យស្ថានភាពធ្ងន់ឡើង។

# ៥. សំណើ វិធីអនុវត្ត វ.ផ.ល. សម្រាប់ប្រទេសកម្ពុជា

## ៥.១. ចំណុចទាំង៧ របស់ វ.ផ.ល.

វ.ផ.ល.គឺការវាយតម្លៃជាប្រព័ន្ធនូវសំណើបញ្ញត្តិកម្មថ្មី (លំហូរនៃបញ្ញត្តិកម្ម) ដោយប្រៀបធៀបបន្ទុកចំណាយនិងផលចំណេញរបស់សំណើបញ្ញត្តិកម្មនោះ ជាមួយនឹងជម្រើសផ្សេងទៀតដែលអាចសម្រេចគោលបំណងបានដូចគ្នា។

វ.ផ.ល. បង្ហាញពីវិធីអនុវត្ត និងធ្វើការវិភាគប្រកបដោយតម្លាភាពឲ្យអ្នកធ្វើសេចក្តីសម្រេច និងភាគីពាក់ព័ន្ធទាំងអស់ (ឧទាហរណ៍ដោយការបោះពុម្ពផ្សព្វផ្សាយឯកសារ វ.ផ.ល. ការវាយតម្លៃបឋម (PA) និងការវាយតម្លៃពេញលេញ (RIS) បង្ហោះលើគេហទំព័រ)។

គោលបំណងចម្បងរបស់ វ.ផ.ល. គឺផ្តល់ព័ត៌មានជូនអ្នកធ្វើសេចក្តីសម្រេច ដើម្បីឲ្យគាត់ធ្វើសេចក្តីសម្រេចប្រកបដោយព័ត៌មានគ្រប់គ្រាន់ទាក់ទងនឹងសំណើបញ្ញត្តិកម្ម។ គោលបំណងឯទៀតរួមមានការផ្តល់ព័ត៌មានឲ្យអ្នកពាក់ព័ន្ធ និងពិគ្រោះយោបល់ជាមួយពួកគេ។

ការវាយតម្លៃជាប្រព័ន្ធដែលបានរៀបរាប់ខាងលើ មានចំណុចចំនួន៧ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ៖

១- បញ្ហា- បង្ហាញហេតុផលនិងភស្តុតាង
២- គោលដៅ- កំណត់គោលដៅឲ្យបានច្បាស់លាស់
៣- ជម្រើស- ពិនិត្យរកជម្រើសផ្សេងក្រៅពីបញ្ញត្តិកម្ម
៤- ផលប៉ះពាល់- វិភាគផលប៉ះពាល់នៃជម្រើសនីមួយៗ
៥- ពិគ្រោះយោបល់- ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ
៦- សន្និដ្ឋាន- ជ្រើសរើសយកជម្រើសដែលមានផលវិជ្ជមានច្រើនបំផុត ប្រសិនបើសំណើបញ្ញត្តិកម្មរឹតត្បិតការប្រកួតប្រជែង ត្រូវធានាថា ការរិតត្បិតនោះត្រូវទទួលបានមកវិញនូវអត្ថប្រយោជន៍សង្គមខ្លាំង។
៧- ការអនុវត្ត- ពិនិត្យឡើងវិញរាល់ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងរៀបចំឲ្យមានរយៈពេលសុពលភាពនៃលិខិតបទដ្ឋានគតិយុត្ត។

ចំណុចទាំង៧នេះ ត្រូវបានយកមកវិភាគម្តងហើយម្តងទៀត ដើម្បីឲ្យកាន់តែសុក្រឹត។ ចំណុចទាំងនេះ មានលក្ខណដូចគ្នានឹងចំណុចណែនាំប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អរបស់អាស៊ាន (GRP 2008) ផ្នែក ៣.១៤។ ប្រទេសអូស្ត្រាលីក៏បានប្រើប្រាស់ចំណុចទាំង៧នេះដែរ។ ប្រព័ន្ធ វ.ផ.ល. ភាគច្រើនប្រើប្រាស់ចំណុចទាំង៧នេះខុសៗគ្នាខ្លះក៏ដោយ ក៏វាមានភាពស្រដៀងគ្នាដែរជារួម។

## ៥.២. ដំណាក់កាលទាំងពីរនៃវិធីអនុវត្ត វ.ផ.ល.

ដើម្បីឲ្យការងាររដ្ឋបាលមានលក្ខណងាយស្រួលនិងនីតិវិធីមានប្រសិទ្ធផល វិធីអនុវត្ត វ.ផ.ល. ដែលមានពីរដំណាក់កាល ត្រូវបានស្នើឡើងសម្រាប់ប្រទេសកម្ពុជា ៖

- នៅដំណាក់កាលដំបូង រាល់សំណើបញ្ញត្តិកម្មទាំងអស់ដែលមានផលប៉ះពាល់ដល់ធុរកិច្ច ត្រូវធ្វើ PA លើកលែងតែសំណើបញ្ញត្តិកម្មដែលមិនមានផលប៉ះពាល់ដល់ធុរកិច្ច។ PA ធ្វើការវិភាគតាមចំណុចទាំង៧ តាមបែបគុណភាពជាមូលដ្ឋាន ទោះបីគួរធ្វើការប៉ាន់ស្មានចំណាយកាតព្វកិច្ចក៏ដោយ
- ប្រសិនបើ PA បង្ហាញថា មានផលប៉ះពាល់គួរកត់សម្គាល់ នោះសំណើបញ្ញត្តិកម្មតម្រូវឲ្យធ្វើការវាយតម្លៃពេញលេញ ហើយចេញជារបាយការណ៍ស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIS)។

តម្លាភាពនិងការពិគ្រោះយោបល់មានសារៈសំខាន់ណាស់ចំពោះ វ.ផ.ល.។ ហេតុដូច្នេះហើយ ទាំងសេចក្តីព្រាងសំណើបញ្ញត្តិកម្ម ទាំងPA និងទាំងRIS គួរត្រូវបង្ហោះលើគេហទំព័រ ដើម្បីឲ្យសាធារណជនបានដឹង។

វ.ផ.ល..គឺជាវិធីអនុវត្តដែលត្រូវយកជម្រើសទាំងអស់មកពិចារណា មុននឹងសម្រេចយកដំណោះស្រាយតាមបែបបញ្ញត្តិកម្ម។ គេទទួលស្គាល់ថាមានហានិភ័យ ដែលរដ្ឋាភិបាលជាញឹកញាប់បានធ្វើបញ្ញត្តិកម្មតែម្តង ដោយមិនបានគិតពិចារណារកជម្រើសផ្សេង - នេះគឺជាការឆ្លើយតបចំពោះបញ្ហាលឿនជ្រុល។

បញ្ញត្តិកម្មធ្វើឲ្យធុរកិច្ចទទួលផលប៉ះពាល់តាមពីរបែប គឺការដាក់បន្ទុកចំណាយកាតព្វកិច្ច និងការផ្លាស់ប្តូរបរិស្ថានប្រកួតប្រជែង។ វិធីអនុវត្ត វ.ផ.ល. នឹងលើកផលប៉ះពាល់ទាំងពីរនេះ។

រូបភាពទី២ (ខាងក្រោម) បង្ហាញពីជំហានក្នុងការធ្វើ PA ដែលបានលម្អិតដូចខាងក្រោម៖

ក. រាល់សំណើត្រូវធ្វើការវាយតម្លៃ ដើម្បីកំណត់ថាតើសំណើទាំងនោះជាបញ្ញត្តិកម្ម ឬយ៉ាងណា។ ដើម្បីងាយយល់ត្រូវសួរថា តើសំណើនោះមានឥទ្ធិពលដល់ធុរកិច្ចដោយផ្ទាល់ ឬដោយប្រយោលឬ? ប្រសិនបើចម្លើយថា "**ទេ**" សំណើនោះមិនមែនបញ្ញត្តិកម្មទេ ហេតុដូចនេះមិនចាំបាច់ធ្វើការវិភាគតទៅទៀតឡើយ។

ខ. រាល់សំណើបញ្ញត្តិកម្មត្រូវធ្វើការវាយតម្លៃថា ដើម្បីកាត់ចោលនូវសំណើបញ្ញត្តិកម្មណាដែលមិនមានផលប៉ះពាល់ដល់ធុរកិច្ចទេ ហើយបើវាមានផលប៉ះពាល់ដល់ធុរកិច្ច ការវិភាគត្រូវបានធ្វើទៅដំណាក់កាលបន្តទៀត។

គ. ហេតុផលសម្រាប់អន្តរាគមន៍របស់រដ្ឋាភិបាល ត្រូវធ្វើការពិនិត្យយ៉ាងដិតដល់។ នេះគឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ធ្វើការវិភាគ និងកំណត់ពីដំណាក់កាលសម្រាប់

ធ្វើការវិភាគបន្តទៀត។ ជាធម្មតាកំហុសនៅដំណាក់កាលនេះ គឺការភាន់ច្រលំរវាងបញ្ហាជាមួយគោលដៅ ហើយផ្អែកលើការសន្មតនិងការអះអាង ជាជាងរកភស្តុតាងជាក់ស្តែង។ ទម្រង់ PA បានរើសយកវិធីជម្រុស ដោយមិនរាប់បញ្ចូលនូវរាល់សំណើបញ្ញត្តិកម្មដែលជាធម្មតាទទួលយកបានជាអន្តរាគមន៍របស់រដ្ឋាភិបាល ដូចជាការពារសុវត្ថិភាពសាធារណៈ និងប្រមូលព័ត៌មាន។

ឃ. ធ្វើបញ្ជីជម្រើសទាំងអស់ដែលធ្វើឲ្យសម្រេចគោលដៅ (ឬក៏ជិតសម្រេចគោលដៅបាន) រួចធ្វើការជ្រើសរើសដោយសម្រិតសម្រាំងយកជម្រើសណាដែលអាចអនុវត្តបាន។

ង. ការពិគ្រោះយោបល់ គឺជាផ្នែកសំខាន់ក្នុងវិធីអនុវត្ត វ.ផ.ល.។ ទោះជាយ៉ាងណាក៏ដោយ នេះជាដំណាក់កាលដំបូង ព្រោះគោលបំណងនៃការពិគ្រោះយោបល់ គឺដើម្បីបំភ្លឺពីបញ្ហា និងធ្វើការប៉ាន់ស្មានដំបូងនៃចំណាយកាតព្វកិច្ចនិងផលប៉ះពាល់ដល់ការប្រកួតប្រជែង។ ដូចនេះ វិធីនេះវាស្រដៀងទៅនឹងការពិគ្រោះយោបល់ជាមួយមនុស្សមួយក្រុម ដើម្បីពិភាក្សាគ្នាលើប្រធានបទអ្វីមួយ។ ការពិគ្រោះយោបល់នេះអាចធ្វើជាមួយសមាគមឧស្សាហកម្មធំៗ ឬធុរកិច្ចដែលរងផលប៉ះពាល់។ សំណើបញ្ញត្តិកម្មត្រូវបង្ហោះលើគេហទំព័ររបស់ក្រសួងសាមី និងបង្ហោះលើគេហទំព័ររបស់ ORIA ហើយក្រសួងសាមីក៏ត្រូវរក្សាទុកដាក់ជាឯកសារសាធារណៈមើលផងដែរ ។

ច. ការបំពេញ PA តម្រូវឲ្យធ្វើការប៉ាន់ស្មានដំបូងនៃវិសាលភាពរបស់សំណើបញ្ញត្តិកម្ម និងផលប៉ះពាល់ដល់ធុរកិច្ច។ លទ្ធផលបានមកពីពិគ្រោះយោបល់ គួរត្រូវយកមកប្រើក្នុងការប៉ាន់ស្មាននេះ។ នៅដំណាក់កាលដំបូងនេះ ការប៉ាន់ស្មានបន្ទុកចំណាយ និងផលចំណេញអាចមានលក្ខណៈជាគុណភាព។ ទោះបីជាយ៉ាងណាក៏ដោយ សម្រាប់បន្ទុកចំណាយកាតព្វកិច្ច ត្រូវធ្វើតាមបែបបរិមាណ។ ការបំពេញទម្រង់ PA ដោយត្រឹមត្រូវ គឺជាការកត់ត្រានូវរបៀបអនុវត្តដែលគួរបង្ហោះលើគេហទំព័ររបស់ ORIA និងរក្សាទុកដាក់ជាឯកសារសាធារណៈនៅក្នុងក្រសួងសាមី (ស្រដៀង នឹង “ង” ខាងលើ)។

ឆ. ប្រសិនបើការវាយតម្លៃបញ្ជាក់ថា មានផលប៉ះពាល់គួរកត់សម្គាល់ នោះតម្រូវឲ្យមានការវាយតម្លៃពេញលេញ(RIS)។ ផ្ទុយទៅវិញ បើមិនមានផលប៉ះពាល់គួរកត់សម្គាល់ទេ ការវិភាគត្រូវបញ្ចប់។ បទពិសោធបង្ហាញថា សំណើបញ្ញត្តិកម្មភាគច្រើនបានបញ្ចប់ការវិភាគត្រឹម PA។

ការវាយតម្លៃពេញលេញ (RIS) តម្រូវឲ្យធ្វើសម្រាប់សំណើបញ្ញត្តិកម្មដែលមានផលប៉ះពាល់គួរកត់សម្គាល់ដល់ធុរកិច្ច។ របៀបធ្វើ RIS មានលក្ខណស្រដៀងនឹង PA ខាងលើដោយហេតុនេះ ចំណុចទាំង៧ត្រូវយកមកវាយតម្លៃ។ កម្រិតនៃការវិភាគត្រូវឲ្យសមនឹងកម្រិតនៃផលប៉ះពាល់របស់សំណើបញ្ញត្តិកម្ម។ ឧទាហរណ៍ សំណើបញ្ញត្តិកម្មដែលមានផលប៉ះពាល់កម្រិតខ្ពស់និងមានវិសាលភាពធំ តម្រូវឲ្យមានការវិភាគបន្ទុកចំណាយនិងផលចំណេញ (CBA) ផ្ទុយទៅវិញសំណើបញ្ញត្តិកម្មណាមានផលប៉ះពាល់តិចតួច ការវាយតម្លៃបែបគុណភាពគឺជាការគ្រប់គ្រាន់។

**លំហូរ: ដំណើរការនៃការវាយតម្លៃបឋម**




ប្រភព: រៀបរៀងដោយអ្នកនិពន្ធ

## ៥.៣. តើវិធីអនុវត្ត វ.ផ.ល. ត្រូវបានដាក់បញ្ចូលក្នុងវិធីនៃការធ្វើសេចក្តីសម្រេចរបស់ទីភ្នាក់ងារអនុវត្ត (IA) ដោយរបៀបណា?

រូបភាពទី៣:ដំណើរការបច្ចុប្បន្នប្រជុំឆ្លងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តក្នុងប្រទេសកម្ពុជា




ប្រភព៖ ផែនការយុទ្ធសាស្ត្រ វ.ផ.ល.របស់ ECOSOCC សីហា ២០១០

ដំណើរការបច្ចុប្បន្នផ្តោតសំខាន់លើទិដ្ឋភាពច្បាប់នៃសេចក្តីព្រាង ថាតើវាស្របទៅនឹងច្បាប់ឬយ៉ាងណា រីឯ វ.ផ.ល. បានផ្តោតសំខាន់លើផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃសំណើបញ្ញត្តិកម្ម ដែលនឹងបំពេញទៅលើដំណើរការបច្ចុប្បន្ន។

## រូបភាពទី៤: ដំណើរការថ្មីនៃការប្រជុំឆ្លងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តក្នុងប្រទេសកម្ពុជា




ប្រភព ៖ ផែនការយុទ្ធសាស្ត្រ វ.ផ.ល.របស់ ECOSOCC សីហា ២០១០

IA រៀបចំផែនការបញ្ញត្តិកម្ម ដែលមានសំណើបញ្ញត្តិកម្មមួយចំនួន ហើយកំពុងពិចារណាអនុវត្ត វ.ផ.ល.។

IA គួរទាក់ទងមន្ត្រីបង្គោលនៃផ្នែក វ.ផ.ល. នៅ ORIA និងសម្រេចពីវិធីសាស្ត្ររបស់ វ.ផ.ល. នៅពេលដែលសំណើបញ្ញត្តិកម្មមួយកំពុងតែពិចារណាគិតគួរនៅដំណាក់កាលធ្វើគោលនយោបាយ ព្រោះវាមានភាពងាយស្រួលអនុវត្ត វ.ផ.ល. ជាងនៅដំណាក់កាលរៀបចំសេចក្តីព្រាង។ IA នឹងរៀបចំ PA ឬ RIS ផ្អែកលើផលប៉ះពាល់គួរកត់សម្គាល់ដូចដែលបានពន្យល់ក្នុងផ្នែក ៥.២ (មើលរូបភាពទី២)។ របាយការណ៍ស្តីពី វ.ផ.ល. នឹងត្រូវបង្ហាញជូនដល់អ្នកធ្វើសេចក្តីសម្រេចមុនពេលសម្រេចទទួលយកសំណើបញ្ញត្តិកម្មនោះ។

## ៥.៤. ទិដ្ឋភាពគន្លឹះនានារបស់ វ.ផ.ល.

សូម្បីតែប្រព័ន្ធ វ.ផ.ល. ដែលបានបង្កើតឡើងយូរមកហើយ ក៏ប្រឈមនឹងការលំបាកក្នុងការអនុវត្តដែរ។ ដូច្នេះ វាមានសារៈសំខាន់ដើម្បីរៀបចំប្រព័ន្ធ វ.ផ.ល. មួយដែលអាចអនុវត្តបានក្នុងប្រទេសកម្ពុជា។

វាជាការងាយណាស់ដោយភ្ជួរផ្លែឈើឲ្យបានទាបដែលអាចស្រួលបេះបាន។ ដូច្នេះដំបូងត្រូវកំណត់ទិសដៅដែលងាយស្រួលសម្រេចបាន មុននឹងឈានដល់ការប្រឈមដែលលំបាកទៅៗ ។ ចំណុចចាំបាច់ជាក់លាក់សម្រាប់ប្រទេសកម្ពុជាគឺ ៖

- **ព័ត៌មាន-** សំណើការអនុវត្ត វ.ផ.ល. នឹងផ្តល់ព័ត៌មានដល់អ្នកធ្វើសេចក្តីសម្រេចពីបន្ទុកចំណាយ និងផលចំណេញរបស់សំណើបញ្ញត្តិកម្ម និងពីជម្រើសផ្សេងៗ ដែលអាចសម្រេចគោលដៅបានដូចគ្នា។ វ.ផ.ល. ធ្វើឲ្យអ្នកធ្វើសេចក្តីសម្រេចចិត្តប្រកបដោយព័ត៌មានគ្រប់គ្រាន់ ដោយគ្មានការរឹតត្បិតដល់ជម្រើសផ្សេងៗ
- **ភាពងាយស្រួល-** អត្ថប្រយោជន៍របស់ វ.ផ.ល. នឹងទទួលបានតាមរយៈការពិគ្រោះយោបល់ ហេតុផលសាមញ្ញ ការគណនាងាយស្រួល និងការសាកល្បងនៃការសន្មត់ដោយម្មត់ចត់ ជាជាងតាមរយៈការអនុវត្តបច្ចេកទេសវិភាគសេដ្ឋកិច្ចស្មុគស្មាញ។ ដូច្នេះ វ.ផ.ល. ក្នុងប្រទេសកម្ពុជាគួរយកទម្រង់តាមការអនុវត្តនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ
- **តម្លាភាព-** តម្លាភាពនាំឲ្យមានការពិគ្រោះយោបល់ដោយប្រសិទ្ធភាព និងអភិបាលកិច្ចល្អ។ ការងារនេះអាចសម្រេចបានដោយចំណាយតិច ដោយបង្ហោះព័ត៌មាននៅលើគេហទំព័រពាក់ព័ន្ធ។ ដើម្បីជួយដល់ធុរកិច្ចធុនតូចដែលមិនមានអ៊ិនធឺណែតប្រើប្រាស់ វិធីទុកដាក់ឯកសារសាធារណៈត្រូវរក្សាទុក ដើម្បីអ្នកចង់មើលក៏អានឯកសារទាំងនោះបាន។

# ៦. រចនាសម្ព័ន្ធ និងមុខងារ

គោលដៅរបស់គម្រោង គឺអនុវត្តការកែទម្រង់បញ្ញត្តិកម្ម ហើយតាមរយៈនេះ ធ្វើឲ្យសម្រេចបាននូវវប្បធម៌នៃការធ្វើគោលនយោបាយឲ្យកាន់តែប្រសើរ និងអភិបាលកិច្ចល្អ។ ដើម្បីសម្រេចបានលទ្ធផលនេះ ការប្រតិបត្តិបានល្អរបស់ ORIA និង IA មានសារៈសំខាន់ណាស់។

លទ្ធផលទាំងបីដែលបានបញ្ជាក់ (មើលផ្នែក២.៤) តម្រូវឲ្យរៀបចំមន្ត្រី ការបែងចែកមុខងារ និងភារកិច្ច និងរចនាសម្ព័ន្ធឲ្យបានសមរម្យ ៖

- លទ្ធផលទី១ ការកសាងសមត្ថភាពមន្ត្រី ORIA និង IA
- លទ្ធផលទី២ ការគាំទ្រផែនការសកម្មភាពធ្វើបញ្ញត្តិកម្មរបស់ក្រសួង (តម្រូវលទ្ធផលទី១)
- លទ្ធផលទី៣ ការអភិវឌ្ឍសហាគមន៍អ្នកអនុវត្តវ.ផ.ល.(ផ្នែកមួយនៃសមត្ថភាពរបស់ORIA)

រូបភាពទី៥: រចនាសម្ព័ន្ធនៃគម្រោង វ.ផ.ល.




ប្រភព: រៀបរៀងដោយអ្នកនិពន្ធ

ORIA មានតួនាទីស្នូលក្នុងការអនុវត្តគម្រោង វ.ផ.ល. ហើយមានមុខងារសំខាន់ៗដូចខាងក្រោម៖

- វាយតម្លៃលើ PA និង RIS ដែលរៀបចំដោយ IA
- បណ្តុះបណ្តាល IA ក្នុងការប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ រួមមានរបៀបនៃការរៀបចំ PA និង RIS និងជួយ IA ក្នុងការរៀបចំ PA និង RIS

- តាមដានការប្រតិបត្តិរបស់IA តាមការប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ និងរៀបចំរបាយការណ៍
- ទំនាក់ទំនងជាមួយ IA ក្រសួងស្ថាប័នផ្សេងទៀត វិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា និងអង្គការពាក់ព័ន្ធផ្សេងទៀត ដើម្បីជំរុញការប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អក្នុងប្រទេសកម្ពុជា។

ORIA មានមន្ត្រី១៨នាក់ មាន៤ផ្នែក ៖ ផ្នែកវ.ផ.ល. ផ្នែCBA ផ្នែកមណ្ឌលព័ត៌មាន និងផ្នែកPIU

- ផ្នែក វ.ផ.ល. ធ្វើការជាមួយនឹង IA ដើម្បីធានាការអនុវត្តការប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ ហេតុដូចនេះ ផ្នែក វ.ផ.ល. មានអនុផ្នែក៤ គឺពាណិជ្ជកម្ម បរិស្ថាន ឧស្សាហកម្ម និង ទេសចរណ៍ ដើម្បីធ្វើទំនាក់ទំនងជាមួយ IA រួមមាន MoC MoE MIME និង MoT។ អនុផ្នែក វ.ផ.ល. មានមន្ត្រីបង្គោលម្នាក់ និងមន្ត្រីជំនួសម្នាក់
- ផ្នែក CBA ផ្តល់ការណែនាំបច្ចេកទេសដល់ផ្នែក វ.ផ.ល. និង IA ដែលពាក់ព័ន្ធនឹងចំណុចទាំង៧នៃវិធីអនុវត្ត វ.ផ.ល. ជាពិសេសវិភាគពីចំណាយកាតព្វកិច្ច និងការវិភាគលើផលប៉ះពាល់។ ផ្នែកនេះក៏រៀបចំផងដែរនូវសកម្មភាពផ្សព្វផ្សាយ និងធ្វើរបាយការណ៍ស្តីពីការប្រតិបត្តិតាម។ របាយការណ៍ស្តីពីការប្រតិបត្តិតាមស្ថិតនៅក្នុងផ្នែក CBA សម្រាប់ការត្រួតពិនិត្យផ្ទៃក្នុងឲ្យកាន់តែល្អ គឺថាការត្រួតពិនិត្យត្រូវបំបែកចេញពីផ្នែក វ.ផ.ល. ដើម្បីធានាថា វ.ផ.ល. ត្រូវបានអនុវត្ត
- មណ្ឌលព័ត៌មានទទួលខុសត្រូវថែទាំមូលដ្ឋានទិន្នន័យ គេហទំព័រ កម្មវិធីកុំព្យូទ័រ និងគ្រឿងបរិក្ខារ IT។ មណ្ឌលព័ត៌មានផ្តល់ការគាំទ្រផ្នែក IT សម្រាប់មន្ត្រី ORIA និង IA។ មណ្ឌលព័ត៌មានទទួលខុសត្រូវផងដែរលើការបញ្ចូលលិខិតបទដ្ឋានគតិយុត្តជាធរមានដែលមានស្រាប់ ទៅក្នុងគេហទំព័រ
- ផ្នែក PIU ទទួលខុសត្រូវការងាររដ្ឋបាល ហិរញ្ញវត្ថុ គណនេយ្យ រៀបចំការបណ្តុះបណ្តាល និងសកម្មភាពផ្សព្វផ្សាយផ្សេងៗ និងផ្តល់សម្ភារៈការិយាល័យ។

IA អនុវត្ត វ.ផ.ល. ដោយមានជំនួយពី ORIA។ ផ្នែក IA មានមន្ត្រី៤នាក់ និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការបញ្ញត្តិកម្ម
- រៀបចំផែនការសកម្មភាព
- ត្រួតពិនិត្យសកម្មភាពបញ្ញត្តិកម្មនៅក្នុងក្រសួងរៀងៗខ្លួន និងធានាថាមានការរៀបចំធ្វើ PA និង RIS ប្រសិនបើចាំបាច់
- ផ្តល់ពិតមានសម្រាប់របាយការណ៍ស្តីពីការប្រតិបត្តិ ដែលតម្រូវតាមពេលកំណត់។

ការបែងចែកមុខងារនិងភារកិច្ចរបស់មន្ត្រីត្រូវបានរៀបចំ ។

រូបភាពទី៦: កិច្ចសហការរវាង ORIA និង IA ក្រាហ្វិកទី១




ប្រភព: រៀបរៀងដោយអ្នកនិពន្ធ

រូបភាពទី៧- កិច្ចសហការរវាង ORIA និង IA ក្រោហ្វិកទី២




ប្រភព : រៀបរៀងដោយអ្នកនិពន្ធ

# ៧. ការគ្រប់គ្រងគម្រោង

## ៧.១. សង្ខេប-លំហូរគម្រោង

ម៉ាទ្រីសស្តីពីសកម្មភាព (មើលសេចក្តីសង្ខេប) ផ្តល់សកម្មភាពខ្លីៗ ដែលបានគ្រោងទុកក្នុងអំឡុងពេលនៃគម្រោង។ សេចក្តីលម្អិតនៃម៉ាទ្រីស និងផែនការគ្រប់គ្រងគម្រោងត្រូវបានរៀបចំឡើងក្នុងកថាខណ្ឌដូចខាងក្រោម។

ពេលវេលាប្រតិបត្តិការគម្រោង ត្រូវបានបែងចែកជាដំណាក់កាលដូចខាងក្រោម៖

**ដំណាក់កាលចាប់ផ្តើម** ក្នុងត្រីមាសចុងក្រោយឆ្នាំ២០១១ បានបង្កើតមូលដ្ឋានគ្រឹះសម្រាប់គម្រោង។ ក្នុងអំឡុងពេលនៃដំណាក់កាលនេះ ORIA និង IA ត្រូវបានបង្កើតឡើង បានរៀបចំមន្ត្រី និងបានប្រតិបត្តិការពេញលេញ។ ដំណើរការការងារ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវបានបង្កើតឡើង ហើយផែនការសកម្មភាពរបស់ IA ក៏ត្រូវបានរៀបចំហើយដែរ (មើលផ្នែក៣.៦ និង៣.៧) ។

គម្រោងឈានដល់**ដំណាក់កាលធ្វើសកម្មភាព**ក្នុងឆ្នាំ២០១២។ ក្នុងអំឡុងពេលនៃដំណាក់កាលនេះមានការបណ្តុះបណ្តាលអំពី វ.ផ.ល. យ៉ាងច្រើន ហើយមន្ត្រីគម្រោងត្រូវបានរំពឹងថាមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងដំណាក់កាលនេះ។

ការជួយពីទីប្រឹក្សាគម្រោងនឹងត្រូវបានកាត់បន្ថយបន្តិចម្តងៗ នៅក្នុងអំឡុង**ដំណាក់កាលពង្រឹងសមត្ថភាពដោយខ្លួនឯង**ក្នុងឆ្នាំ២០១៣។ មន្ត្រីគម្រោងត្រូវបានរំពឹងថានឹងអនុវត្ត វ.ផ.ល. ដោយមានជំនួយតិចតួចពីទីប្រឹក្សាគម្រោង។

ការជួយជ្រុំជ្រែងពីទីប្រឹក្សាគម្រោង នឹងបញ្ចប់នៅ**ដំណាក់កាលវាយតម្លៃ**នាខែធ្នូ ឆ្នាំ២០១៣/ខែមករា ឆ្នាំ២០១៤។ ប្រធានក្រុមទីប្រឹក្សា ទីប្រឹក្សាសេដ្ឋកិច្ចបញ្ញត្តិកម្មអន្តរជាតិ និងទីប្រឹក្សាឯកទេសផ្នែកយេនឌ័រនឹងបំពេញការងារក្នុងរយៈពេលតិចជាងមួយខែ ដើម្បីរៀបចំរបាយការណ៍វាយតម្លៃលើគម្រោង។ ទោះបីជាយ៉ាងណាក៏ដោយ ការគាំទ្រផ្នែករដ្ឋបាលសម្រាប់គម្រោងនៅតែបន្តរហូតដល់ចប់គម្រោងនៅខែមិនា ឆ្នាំ២០១៤។ ទីប្រឹក្សាអភិបាលគម្រោងនឹងបំពេញការងាររហូតដល់ចប់គម្រោង ដោយធ្វើការកន្លះថ្ងៃដែលគិតសរុបស្មើនឹង១៨ខែ។ ឌីយ៉ាក្រាមខាងក្រោមបានសង្ខេបដំណើរការនេះ។

កិច្ចពិភាក្សាខាងក្រោមនេះ គឺសំដៅទៅលើចំណុចដូចតទៅ ៖

- សកម្មភាពដែលទាក់ទងនឹងលទ្ធផលទី១ (ផ្នែក៧.២) និងលទ្ធផលទី២ (ផ្នែក៧.៣) ក្នុងអំឡុងពេលនៃដំណាក់កាលចាប់ផ្តើម និងដំណាក់កាលធ្វើសកម្មភាព
- សកម្មភាពដែលទាក់ទងនឹងការបណ្តុះបណ្តាលនៅបរទេស (ផ្នែក៧.៤)

- សកម្មភាពដែលទាក់ទងនឹងលទ្ធផលទី៣ (ផ្នែក៧.៥) និង
- សកម្មភាពដែលអនុវត្តអំឡុងដំណាក់កាលពង្រឹងសមត្ថភាពដោយខ្លួនឯង និងដំណាក់កាលវាយតម្លៃ (ផ្នែក៧.៦)។

ការបញ្ជាក់ពីថវិកា និងពេលវេលាប្រតិបត្តិត្រូវបានរៀបចំឡើង និងដាក់ជូនសមាជិកនៃគណៈកម្មាធិការនាយករបស់គម្រោង។ ថវិកាគឺជាបញ្ហារសើបដែលត្រូវបានសម្រេចមិនឲ្យផ្សព្វផ្សាយនៅដំណាក់កាលនេះ។ ដូច្នេះថវិកាត្រូវបានបញ្ចូលក្នុងឧបសម្ព័ន្ធ៤ ជាឯកសារសម្ងាត់។

តារាង២ : ទិដ្ឋភាពរួម រយៈពេលគម្រោងនិងការចូលរួមពីទីប្រឹក្សាគម្រោង

| | ២០១១ | ២០១២ | | | | ២០១៣ | | | | ២០១៤ |
|---|---|---|---|---|---|---|---|---|---|---|
| | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ |
| រយៈពេលគម្រោង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ដំណាក់កាលដំបូង | ■ | | | | | | | | | |
| ដំណាក់កាលធ្វើសកម្មភាព | | ■ | ■ | ■ | ■ | | | | | |
| ដំណាក់កាលពង្រឹងសមត្ថភាព | | | | | | ■ | ■ | ■ | ■ | |
| ដំណាក់កាលវាយតម្លៃ | | | | | | | | | ■ | ■ |
| ការចូលរួមរបស់ទីប្រឹក្សាគម្រោង | | | | | | | | | | |
| ប្រធានក្រុមទីប្រឹក្សា (១២ខែ) | ■ | ■ | ■ | ■ | ■ | ■ | | | | ■ |
| ទីប្រឹក្សាសេដ្ឋកិច្ចបញ្ញត្តិកម្មអន្តរជាតិ(១២ខែ) | | ■ | ■ | ■ | ■ | ■ | ■ | | | ■ |
| ទីប្រឹក្សាអភិបាលគម្រោង(១៨ខែ) | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ទីប្រឹក្សាឯកទេសផ្នែកយេនឌ័រ(១២ខែ) | ■ | ■ | ■ | ■ | ■ | ■ | | | | ■ |

## ៧.២. លទ្ធផលទី១- ការកសាងសមត្ថភាពនៅក្នុងក្រុមអនុវត្តគម្រោង (ORIA) និងទីភ្នាក់ងារអនុវត្តគម្រោង IA

សកម្មភាពដែលទាក់ទងនឹងលទ្ធផលនេះចែកជាពីរប្រភេទធំៗ៖

- បង្កើតរចនាសម្ព័ន្ធ រៀបចំមន្ត្រី និងដំណើរការការងារ។

- កសាងសមត្ថភាពមន្ត្រីដោយធ្វើការបណ្តុះបណ្តាលពួកគាត់និងផ្តល់ឯកសារណែនាំចាំបាច់ដើម្បីអនុវត្ត វ.ផ.ល.។

ភាគច្រើននៃសកម្មភាពទាំងនេះនឹងត្រូវបានបញ្ចប់រហូតដល់ចុងឆ្នាំ២០១២ ហើយក្នុងឆ្នាំ២០១៣ គម្រោងនឹងឈានដល់ដំណាក់កាលពង្រឹង ដោយមានជំនួយបន្តិចបន្តួចពីក្រុមទីប្រឹក្សា ដើម្បីជាចម្បងដោះស្រាយការខ្វះខាតដែលកើតឡើងដោយមិនបានរំពឹងទុកប៉ុណ្ណោះ។

ទោះបីលទ្ធផលនេះសំដៅសម្រាប់ ORIA ក៏ដោយ ក៏វាមានប្រសិទ្ធភាពច្រើនដែរក្នុងការអនុវត្តសកម្មភាពទាំងនេះសម្រាប់ IA ក្នុងពេលជាមួយគ្នា ដោយសារមានកិច្ចសហការគ្នាទៅវិញទៅមករវាង ORIA និង IA។ អនុវត្តសកម្មភាពទាំងនេះជាមួយគ្នា គឺធ្វើឲ្យមន្ត្រីគម្រោងទាំងមូលបង្កើតជាក្រុមមួយល្អ និងមានទំនាក់ទំនងគ្នាបានកាន់តែប្រសើរឡើង។

## ដំណាក់កាលចាប់ផ្តើម

មានការងារសំខាន់ៗជាច្រើនដែលត្រូវបានធ្វើនៅដំណាក់កាលចាប់ផ្តើម (និងមុន) ក្នុងការបង្កើត ORIA។ កិច្ចប្រជុំជាច្រើនបានរៀបចំឡើងក្នុងអំឡុងពេលនៃដំណាក់កាលចាប់ផ្តើម ដើម្បីរៀបចំ និងពន្យល់ពីរចនាសម្ព័ន្ធដល់មន្ត្រី ORIA និង IA។ ការបែងចែកមុខងារ និងភារកិច្ចរបស់មន្ត្រីត្រូវបានរៀបចំឡើង។

វគ្គបណ្តុះបណ្តាលចំនួន៣ ស្តីពី វ.ផ.ល. ប្រព័ន្ធត្រួតពិនិត្យនិងរបៀបរបបធ្វើការងារ ត្រូវបានរៀបចំឡើងសម្រាប់មន្ត្រី ORIA និង IA ក្នុងអំឡុងពេលនៃដំណាក់កាលចាប់ផ្តើម។ កិច្ចសហការរវាង ORIA និង IA បានសង្ខេបក្នុងរូបភាពទី៦ និងទី៧នៃផ្នែក៦។ វគ្គបណ្តុះបណ្តាលអំពីបញ្ហាយេនឌ័រក្នុង វ.ផ.ល. ក៏បានរៀបចំផងដែរ។

ឯកសារ វ.ផ.ល. ភាគច្រើន (ក្រៅពីសៀវភៅណែនាំ) ត្រូវបានរៀបចំហើយ និងបានបកប្រែជាភាសាខ្មែរក្នុងអំឡុងពេលនៃដំណាក់កាលចាប់ផ្តើម (មើលផ្នែក៣.៦)។

ORIAបានប្រតិបត្តិការយ៉ាងពេញលេញក្នុងដំណាក់កាលចាប់ផ្តើមនេះ(មើលផ្នែក៣.២)។ ការរៀបចំបែបបទដើម្បីទិញគ្រឿងបរិក្ខារកំពុងដំណើរការ (បញ្ជីគ្រឿងបរិក្ខារដែលត្រូវទិញនៅឧបសម្ព័ន្ធ១) ហើយរំពឹងថានឹងបញ្ចប់រហូតដល់ត្រីមាសទី១ ឆ្នាំ២០១២។

## ដំណាក់កាលធ្វើសកម្មភាព

ការបណ្តុះបណ្តាលបន្ថែមស្តីពីដំណើរការការងារ ប្រព័ន្ធត្រួតពិនិត្យ និងការរៀបចំរបាយការណ៍ នឹងបន្តក្នុងត្រីមាសទី១ ឆ្នាំ២០១២។ ការបណ្តុះបណ្តាលកម្រិតស៊ីជម្រៅស្តីពី វ.ផ.ល. និង CBA នឹងរៀបចំឡើងសម្រាប់មន្ត្រី ORIA និង IA ក្នុងត្រីមាសទី១និងត្រីមាសទី២ ឆ្នាំ២០១២។ សកម្មភាពបណ្តុះបណ្តាលនេះត្រូវបានរៀបចំនៅទីស្តីការគណៈរដ្ឋមន្ត្រី។ ការ

បណ្តុះបណ្តាលបែបនេះនឹងត្រូវកាត់បន្ថយជាបណ្តើរៗនៅឆមាសទី២ ឆ្នាំ២០១២។ ក្នុងអំឡុងពេលនេះ ទីប្រឹក្សាគម្រោងនឹងចុះបណ្តុះបណ្តាលដោយផ្ទាល់ដល់ទីកន្លែងIAនីមួយៗ ដើម្បីអនុវត្ត វ.ផ.ល.។ ក្នុងឆ្នាំ២០១២ ការបណ្តុះបណ្តាលនឹងផ្លាស់ប្តូរពីការបង្រៀនមកការរៀនដោយអនុវត្តផ្ទាល់។

ឯកសារ វ.ផ.ល.ទាំងអស់ (ទម្រង់បញ្ជីត្រួតពិនិត្យ និងគោលការណ៍ណែនាំ) នឹងបោះពុម្ពផ្សព្វផ្សាយនៅត្រីមាសទី១ ឆ្នាំ២០១២។ សៀវភៅណែនាំអំពី វ.ផ.ល. នឹងត្រូវរៀបចំ និងបោះពុម្ពនៅត្រីមាសទី២ ឆ្នាំ២០១២។

ក្នុងត្រីមាសទី៤ ឆ្នាំ២០១១ ផ្នែក IT បានបញ្ចប់ការសាកល្បងមូលដ្ឋានទិន្នន័យ និងគេហទំព័រដែលនឹងប្រតិបត្តិការពេញលេញនៅត្រីមាសទី១ ឆ្នាំ២០១២។ ក្នុងអំឡុងពេលដើមឆមាសទី១ ឆ្នាំ២០១២ មណ្ឌលព័ត៌មាន (i-Centre) នឹងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រី ORIA និង IA ពីរបៀបប្រើប្រាស់មូលដ្ឋានទិន្នន័យនិងគេហទំព័រ។ មណ្ឌលព័ត៌មានក៏ផ្តល់ការបណ្តុះបណ្តាលពីការប្រើប្រាស់កម្មវិធី និងគ្រឿងបរិក្ខារកុំព្យូទ័រឲ្យមានប្រសិទ្ធភាពផងដែរ។ ផ្នែក IT នឹងបន្តកែលម្អគេហទំព័រនិងមូលដ្ឋានទិន្នន័យ និងផ្តល់ការគាំទ្រដល់មន្ត្រី ORIA និង IA រហូតដល់ចប់គម្រោង។

ផ្នែក IT នឹងបញ្ចូលទិន្នន័យលិខិតបទដ្ឋានគតិយុត្តជាធរមានដែលមានស្រាប់ (ក្រៅពីប្រកាស) ក្នុងមូលដ្ឋានទិន្នន័យនៅឆមាសទី១ ឆ្នាំ២០១២។ ទិន្នន័យទាំងនេះមានរួចហើយនៅក្នុងស្ថាប័នឯទៀតរបស់រាជរដ្ឋាភិបាល។ ដូច្នេះ វាអាចមានលទ្ធភាពបញ្ចូលទិន្នន័យទាំងនេះក្នុងមូលដ្ឋានទិន្នន័យរបស់ ORIA ដោយប្រព័ន្ធអេឡិចត្រូនិកបាន។ ជម្រើសផ្សេងទៀតគឺបញ្ចូលដោយដៃ។ ជម្រើសទាំងពីរនេះនឹងត្រូវបានវាយតម្លៃ និងសម្រេចយកមួយណាដែលល្អជាងគេនៅដើមឆ្នាំ២០១២។

ផ្នែក IT ក៏នឹងពិនិត្យថាតើអាចបញ្ចូលប្រកាសរបស់ IA ក្នុងមូលដ្ឋានទិន្នន័យបានឬយ៉ាងណាដែរ។ ប្រសិនបើធ្វើបាននោះ កិច្ចការនេះអាចអនុវត្តនៅចុងឆ្នាំ២០១២ និងដើមឆ្នាំ២០១៣។

មានការត្រៀមបម្រុងទុកសម្រាប់ជួលទីប្រឹក្សាខាងក្រៅ ដើម្បីសិក្សា អង្កេត ឬបង្កើតប្រព័ន្ធ IT បន្ថែម។ លក្ខណៈពិតប្រាកដនៃបញ្ហានេះនឹងត្រូវបានកំណត់ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១២។

### ៧.៣.លទ្ធផលទី២- ការគាំទ្រផែនការសកម្មភាពរបស់ទីភ្នាក់ងារគម្រោង (IA)

IA ទាំង៤របស់ MoC MoE MIME និង MoT បានរៀបចំវិធានការ ដើម្បីអនុវត្តគម្រោងសាកល្បងរបស់រាជរដ្ឋាភិបាល។ រដ្ឋមន្ត្រីនៃក្រសួងទាំង៤នេះ បានបង្កើតផ្នែក វ.ផ.ល. ជាផ្លូវការរួមទាំងការតែងតាំងមន្ត្រី វ.ផ.ល. ផងដែរ។

ផ្នែកសំខាន់នៃលទ្ធផលទី២នេះ គឺកសាងសមត្ថភាពតាមរយៈការបណ្ដុះបណ្ដាលដោយផ្ទាល់មួយទល់មួយ និងផ្ដល់ការបណ្ដុះបណ្ដាលមន្ត្រី វ.ផ.ល. នៅតាមការិយាល័យប្រតិបត្តធ្វើបញ្ញត្តិកម្មល្អ នៅបរទេស។ លើសពីនេះទៀត ក៏មានការគាំទ្រដល់ការរៀបចំការិយាល័យ IA របៀបរបបធ្វើការងារ និងប្រព័ន្ធ IT ក៏ត្រូវបានផ្ដល់ជូនផងដែរ។

ដូចមានចែងក្នុងផ្នែកមុនផងដែរ ភាគច្រើននៃសកម្មភាពទាំងនេះនឹងបញ្ចប់រហូតដល់ចុងឆ្នាំ២០១២ ហើយក្នុងឆ្នាំ២០១៣ គម្រោងនឹងឈានដល់ដំណាក់កាលពង្រឹង ដោយមានជំនួយបន្តិចបន្តួចពីក្រុមទីប្រឹក្សា ដើម្បីជាចម្បងដោះស្រាយការខ្វះខាតដែលកើតឡើងដោយមិនបានរំពឹងទុកប៉ុណ្ណោះ។

### ដំណាក់កាលចាប់ផ្ដើម

កិច្ចប្រជុំជាច្រើនត្រូវបានរៀបចំឡើងជាមួយមន្ត្រី IA មានការជួបជាលក្ខណបុគ្គល និងជារួមក្នុងអំឡុងពេលនៃដំណាក់កាលចាប់ផ្ដើម។ ក្នុងអំឡុងពេលសិក្ខាសាលាពិគ្រោះយោបល់នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១ ដែលមានការចូលរួមពីសំណាក់មន្ត្រីគម្រោងភាគច្រើន មន្ត្រីIA បានសំដែងទស្សនៈអំពីវិធីអនុវត្តគម្រោងឲ្យបានល្អប្រសើរ។ ទស្សនៈ និងក្ដីបារម្ភរបស់ពួកគេក៏បានលើកឡើងផងដែរនៅក្នុងកិច្ចប្រជុំបន្តបន្ទាប់មកទៀតនិងបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ស្ដីពីការចាប់ផ្ដើមនេះ។

មន្ត្រី IA ត្រូវបានស្នើឲ្យរៀបចំផែនការបញ្ញត្តិកម្ម ដោយបញ្ចូលសំណើបញ្ញត្តិកម្មមួយចំនួន (មានលិខិតបទដ្ឋានគតិយុត្តជាធរមានដែលមានស្រាប់ សម្រាប់អនុវត្ត វ.ផ.ល.ប៉ុណ្ណោះ) ដែល IA មានផែនការអនុវត្ត វ.ផ.ល.។ ទម្រង់ផែនការបញ្ញត្តិកម្មមានភ្ជាប់នៅឧបសម្ព័ន្ធ៣ (មើលផ្នែក៣.៦)។ ផែនការបញ្ញត្តិកម្ម គឺជាឯកសារការងារដែលព្រមព្រៀងគ្នារវាង IA និង ORIA។ ទម្រង់នេះនឹងជួយរៀបចំផែនការសកម្មភាពនៃបញ្ញត្តិកម្ម និងទំហំការងារ ហើយធ្វើឲ្យដំណើរការប្រកបដោយព័ត៌មាន និងតម្លាភាព។ វគ្គបណ្ដុះបណ្ដាលពីរបៀបនៃការរៀបចំផែនការបញ្ញត្តិកម្មត្រូវបានប្រព្រឹត្តទៅនៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១។

មន្ត្រី IA នានាបានលើកឡើងថា ពួកគេត្រូវពិគ្រោះយោបល់ជាមួយនាយកដ្ឋានទាំងអស់នៅក្នុងក្រសួងរបស់ពួកគេសិន ដើម្បីរៀបចំផែនការនេះ។ មន្ត្រី IA ខ្លះស្ថិតនៅបរទេស (ឧទា. មន្ត្រី MoC ទៅ Geneva ដើម្បីធ្វើការជាមួយ WTO)។ ហេតុនេះ មានការលំបាកក្នុងការបញ្ចប់ផែនការឲ្យទាន់ពេលវេលា ដើម្បីបញ្ចូលទៅក្នុងរបាយការណ៍ស្ដីពីការចាប់ផ្ដើម។ ដូច្នេះ មានការយល់ព្រមថា ផែនការសកម្មភាពបឋមនឹងត្រូវបានបញ្ចប់នៅអំឡុងពេលនៃដំណាក់កាលចាប់ផ្ដើមផែនការបឋមនេះនឹងធ្វើបច្ចុប្បន្នភាពនៅត្រីមាសទី១ ឆ្នាំ២០១២ ហើយនឹងត្រូវបញ្ចូលក្នុងរបាយការណ៍ប្រចាំឆមាសក្នុងខែមីនា ឆ្នាំ២០១៣។

ដូច្នោះ IA នីមួយៗរៀបចំផែនការបញ្ញត្តិកម្ម ដែលត្រូវបានចែកជូនគ្រប់ IA ហើយដាក់ពិភាក្សាក្នុងកិច្ចប្រជុំនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១។

ម្យ៉ាងទៀត ការបណ្តុះបណ្តាលដំបូងត្រូវបានរៀបចំសម្រាប់មន្ត្រីគម្រោង ដើម្បីអនុវត្ត PA។ ទម្រង់ពាក់ព័ន្ធបញ្ជីត្រួតពិនិត្យ និងឯកសារណែនាំជាភាសាខ្មែរត្រូវបានផ្តល់ទៅឲ្យពួកគេ។ វគ្គ បណ្តុះបណ្តាលស្តីពីបញ្ហាយេនឌ័រក៏បានរៀបចំសម្រាប់ពួកគេផងដែរ។

### ដំណាក់កាលធ្វើសកម្មភាព

ផ្តល់ការបណ្តុះបណ្តាលស្តីពី វ.ផ.ល. ដល់មន្ត្រីគម្រោងរយៈពេលពេញមួយឆ្នាំ២០១២។ មន្ត្រី ORIA ក៏ត្រូវចូលរួមវគ្គបណ្តុះបណ្តាលនេះផងដែរ (បណ្តុះបណ្តាលអ្នកបណ្តុះបណ្តាល) ដើម្បីឲ្យពួកគេអាចបន្តបណ្តុះបណ្តាល IA បន្ទាប់ពីបញ្ចប់គម្រោង។ ដូចការដែលបានបញ្ជាក់នៅផ្នែកមុន ផែនការបញ្ញត្តិកម្មនឹងបញ្ចប់នៅដើមឆ្នាំ២០១២។

ទីប្រឹក្សាអន្តរជាតិ និងមន្ត្រី ORIA នឹងធ្វើការនៅការិយាល័យរបស់ IA មួយរយៈពេល ដើម្បីបណ្តុះបណ្តាលមន្ត្រី IA ក្នុងអំឡុងឆ្នាំ២០១២។ ទីប្រឹក្សាអន្តរជាតិនឹងផ្លាស់ប្តូរពេលវេលារបស់ពួកគេ ក្នុងចំណោមក្រសួងនានាឲ្យបានច្រើនតាមតែអាចធ្វើទៅបាន ដើម្បីជួយ IA ឲ្យសម្រេចផែនការបញ្ញត្តិកម្មរបស់ពួកគេ។

មន្ត្រី IA និង ORIA នឹងរៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីចែករំលែកព័ត៌មាន និងតាមដានវឌ្ឍនភាពរបស់គម្រោង។

## ៧.៤.លទ្ធផលទី១ និងទី២- ទស្សនកិច្ចសិក្សា និងការបណ្តុះបណ្តាលនៅបរទេស

ថវិកាសម្រាប់បណ្តុះបណ្តាលមួយផ្នែកធំ ត្រូវបានបែងចែកដល់ការបណ្តុះបណ្តាលនៅការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ(OBPR) នៅបរទេស។ សកម្មភាពទាំងនេះពាក់ព័ន្ធនឹងលទ្ធផលទី១ និងទី២ ពីព្រោះទាំងមន្ត្រី ORIA ទាំង IA នឹងទទួលការបណ្តុះបណ្តាលនៅបរទេស។ ហេតុដូច្នេះហើយ បញ្ហាការបណ្តុះបណ្តាលនៅបរទេសត្រូវបានពិភាក្សាដាច់ដោយឡែកនៅក្នុងផ្នែកនេះ។

សកម្មភាពពីរប្រភេទត្រូវបានគ្រោងនឹងធ្វើក្នុងអំឡុងឆ្នាំ២០១២ គឺទស្សនកិច្ចសិក្សា និងការបញ្ជូនទៅធ្វើការនៅបរទេស ៖

- ទស្សនកិច្ចសិក្សាមានរយៈពេលប្រហែលមួយសប្តាហ៍ ដែលមានគោលបំណងផ្តល់ឱកាសដល់មន្ត្រីជាន់ខ្ពស់សិក្សាស្វែងយល់ពីការប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ។
  មន្ត្រីជាន់ខ្ពស់នឹងជួបជាមួយមន្ត្រីជាន់ខ្ពស់មកពីការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ (OBPR) ដើម្បីរៀនសូត្របទពិសោធពីគេ។ ទស្សនកិច្ចសិក្សានឹងធ្វើនៅការិយាល័យ

ប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ (OBPR) ផ្សេងៗ ដែលអាចឲ្យមន្ត្រីជាន់ខ្ពស់ ORIA និង IA ទទួលបានបទពិសោធទូលំទូលាយ អាចចែករំលែករវាងគ្នាទៅវិញទៅមក

- ការបញ្ជូនទៅធ្វើការមានរយៈពេល២-៣ សប្តាហ៍ គឺមានបំណងផ្តល់ឱកាសដល់មន្ត្រីបច្ចេកទេស ធ្វើការជាមួយមន្ត្រីបច្ចេកទេសរបស់ការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ (OBPR) នៅបរទេស។ ការរៀបចំនេះនឹងមានការចរចារជាមួយការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ(OBPR) នៅបរទេស ដើម្បីរៀបចំការបណ្តុះបណ្តាលនេះ។

ការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ(OBPR) នៅលើពិភពលោក ដែលសមរម្យសម្រាប់រៀបចំការបណ្តុះបណ្តាលបែបនេះ មាន ៖

- នៅប្រទេសប្រទេសអូស្ត្រាលី គឺការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ (Office of Best Practice Regulation) (OBPR, Australian Commonwealth)
- នៅប្រទេសរដ្ឋវិចតូរិយ៉ា (Victoria) ប្រទេសអូស្ត្រាលី-គណៈកម្មការប្រសិទ្ធផល និងការប្រកួតប្រជែងរដ្ឋវិចតូរិយ៉ា (Victoria Competition and Efficient Commission-(VCEC))
- នៅប្រទេសរដ្ឋនៅប្រទេសអូស្ត្រាលីផ្សេងទៀត ដូចជា New South Wales and Adelaide
- នៅប្រទេសប្រទេសញូសេឡែន (New Zealand) អង្គភាពវិភាគផលប៉ះពាល់បញ្ញត្តិកម្ម (Regulatory Impact Analysis (RIAU))
- នៅប្រទេសចក្រភពអង់គ្លេស (United Kingdom) Better Regulation Executive (BRE)
- នៅប្រទេសសហរដ្ឋអាមេរិក (United States) ការិយាល័យព័ត៌មាននិងកិច្ចការបញ្ញត្តិកម្ម (Office of Information and Regulatory Affairs (OIRA))

សេចក្តីលម្អិតអំពីសកម្មភាពនៅបរទេស នឹងចរចារជាមួយការិយាល័យប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ(OBPR) នៅបរទេស និងបញ្ចប់ក្នុងត្រីមាសទី១ ឆ្នាំ២០១២។ មន្ត្រីដែលត្រូវធ្វើការបណ្តុះបណ្តាលនៅបរទេសនឹងត្រូវជ្រើសរើសចេញពីមន្ត្រី ORIA និង IA ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានព្រមព្រៀងជាមួយ ADB។

### ៧.៥.លទ្ធផលទី៣- ការបង្កើតសហគមន៍អ្នកអនុវត្ត វ.ផ.ល.

សិក្ខាសាលាទ្រង់ទ្រាយធំចំនួន៣ត្រូវបានគ្រោងនឹងធ្វើឡើង។ អ្នកដែលត្រូវការអញ្ជើញឲ្យចូលរួមក្នុងសិក្ខាសាលានេះរួមមានថ្នាក់ដឹកនាំក្រសួងស្ថាប័ន តំណាងវិស័យឯកជន ដៃគូអភិវឌ្ឍសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ។ គោលបំណងនៃសិក្ខាសាលានេះ គឺដើម្បីជំរុញការប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ និងផ្សព្វផ្សាយព័ត៌មានអំពីគម្រោង វ.ផ.ល. ដល់ក្រសួងស្ថាប័នឯទៀតនៃរាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន និងគ្រឹះស្ថានឧត្តមសិក្សា។ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានប្រើប្រាស់ដើម្បីផ្សព្វផ្សាយពីសកម្មភាពរបស់គម្រោងដល់ធុរកិច្ច និងសហគមន៍។

- សិក្ខាសាលាទ្រង់ទ្រាយធំលើកទី១ គ្រោងនឹងធ្វើនៅដើមឆ្នាំ២០១២ ដើម្បីសម្ពោធដាក់ឲ្យដំណើរការគម្រោង វ.ផ.ល. ជាផ្លូវការ និងបង្ហាញពីរបាយការណ៍ស្តីពីការចាប់ផ្តើមអនុវត្តគម្រោង
- សិក្ខាសាលាទ្រង់ទ្រាយធំលើកទី២ គ្រោងនឹងធ្វើនៅចុងឆ្នាំ២០១២ ឬដើមឆ្នាំ២០១៣ ដើម្បីបង្ហាញពីរបាយការណ៍ស្តីពីវឌ្ឍនភាព
- សិក្ខាសាលាទ្រង់ទ្រាយធំលើកទី៣ គ្រោងនឹងធ្វើនៅខែមករា ឆ្នាំ២០១៤ ដើម្បីបង្ហាញពីរបាយការណ៍ស្តីពីការបញ្ចប់គម្រោង។

បន្ថែមលើសិក្ខាសាលាទាំងនេះ មានកិច្ចប្រជុំប្រចាំត្រីមាសនៅរាជធានីភ្នំពេញ (លើកលែងតែត្រីមាសណាជាន់នឹងកម្មវិធីសិក្ខាសាលាទ្រង់ទ្រាយធំ) ដែលមានគោលបំណងកសាងសហគមន៍អ្នកអនុវត្ត វ.ផ.ល. និងជំរុញការរៀបចំគោលនយោបាយដោយផ្អែកលើភស្តុតាង។ កិច្ចប្រជុំនេះនឹងផ្តល់ឱកាសដល់មន្ត្រីគម្រោងជួបជាមួយអ្នកអនុវត្ត វ.ផ.ល. ពីក្រសួងស្ថាប័នអ្នកសេដ្ឋកិច្ច អ្នកដឹកនាំធុរកិច្ច សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ។

## ៧.៦.ដំណាក់កាលពង្រឹង និងវាយតម្លៃ

### ដំណាក់កាលពង្រឹង

ការពិនិត្យថាតើប្រព័ន្ធ វ.ផ.ល. ត្រូវបានអនុវត្តដោយរបៀបណា នឹងធ្វើឡើងនៅត្រីមាសទី១ ឆ្នាំ២០១៣។ ការពិនិត្យនេះនឹងគ្របដណ្តប់លើសកម្មភាព វ.ផ.ល. ទាំងមូល (លទ្ធផលទី១ លទ្ធផលទី២ និងទី៣)។ ក្នុងអំឡុងពេលនៃដំណាក់កាលនេះ គឺផ្តោតសំខាន់ទៅលើការដោះស្រាយការខ្វះខាតនានា (រួមបញ្ចូលទាំងតម្រូវការបណ្តុះបណ្តាល) ដើម្បីឲ្យគម្រោង អាចដំណើរការបានដោយប្រសិទ្ធភាពដោយគ្មានការគាំទ្រពីទីប្រឹក្សា។

ឯកសារស្តីពី វ.ផ.ល. នឹងត្រូវធ្វើបច្ចុប្បន្នភាព ផ្អែកលើបទពិសោធ ដែលទទួលបានក្នុងអំឡុងពេលនៃដំណាក់កាលធ្វើសកម្មភាព។

### ដំណាក់កាលវាយតម្លៃ

នៅខែធ្នូ ឆ្នាំ២០១៣ /ខែមករា ឆ្នាំ២០១៤ នឹងមានការវាយតម្លៃលើវឌ្ឍនភាពរបស់គម្រោង វ.ផ.ល. ជាពិសេសផ្តោតលើដំណាក់កាលដែលគ្មានជំនួយពីក្រុមទីប្រឹក្សាគម្រោង។ របាយការណ៍នឹងត្រូវបានរៀបចំនៅចុងខែមករា ឆ្នាំ២០១៤។

## ៨.ផែនការសកម្មភាពយេនឌ័រ

គោលបំណងនៃផែនការសកម្មភាពយេនឌ័រ គឺធ្វើឲ្យបានសម្រេចសមធម៌យេនឌ័រក្នុងការតាក់តែងធ្វើបញ្ញត្តិកម្មនៅក្នុងប្រទេសកម្ពុជា។ ពោលគឺ ដើម្បីធានាថា អ្នកទាំងឡាយដែលបានចូលរួមក្នុងការតាក់តែងធ្វើបញ្ញត្តិកម្ម មានការយល់ដឹងពីសំណើបញ្ញត្តិកម្មដែលអាចមានផលប៉ះពាល់លើស្ត្រី និងផ្តល់ព័ត៌មានជូនអ្នកធ្វើសេចក្តីសម្រេច (ដោយបញ្ចូលព័ត៌មានពាក់ព័ន្ធក្នុងរបាយការណ៍ស្តីពី វ.ផ.ល.) ពីផលប៉ះពាល់អវិជ្ជមានទៅលើស្ត្រី។

គោលបំណងនេះស្របនឹងគោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជាលេខ៣ (CMDG3) ដែលលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី។ បុរសនិងស្ត្រីនៅក្នុងប្រទេសកម្ពុជាមានបញ្ហានិងអត្ថប្រយោជន៍ផ្សេងៗគ្នា។ ដូច្នេះហើយ ពួកគេអាចទទួលរងផលប៉ះពាល់ ផ្សេងៗគ្នាពីបញ្ញត្តិកម្ម ទោះបីជាបញ្ញត្តិកម្មនោះអនុវត្តចំពោះពួកគេដោយស្មើភាពគ្នាក៏ដោយ។

ប្រព័ន្ធ វ.ផ.ល. នៅប្រទេសគេជាច្រើនមិនមានសមាសធាតុយេនឌ័រទេ។ ម្យ៉ាងទៀត គោលការណ៍ណែនាំប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អរបស់អាស៊ាន ក៏មិនមានបញ្ហាយេនឌ័រជាក់លាក់ដែរ។ ទោះបីជាយ៉ាងណាក៏ដោយ នេះជាបញ្ហាពាក់ព័ន្ធនឹងប្រទេសកម្ពុជា ដែលអាចបណ្តាលឲ្យស្ត្រីទទួលរងផលប៉ះពាល់ផ្សេង ដូចជានៅក្នុងឧស្សាហកម្មកាត់ដេរធំៗ ដែលផ្តល់ការងារដល់ស្ត្រីជាច្រើន។ ម្យ៉ាងទៀត កង្វះការពិគ្រោះយោបល់ក្នុងអំឡុងពេលនៃការតាក់តែងធ្វើបញ្ញត្តិកម្ម និងកង្វះតំណាងស្ត្រី អាចនាំឲ្យមានអសមធម៌យេនឌ័រនៅក្នុងការធ្វើបញ្ញត្តិកម្ម។

ហេតុនេះ ទីប្រឹក្សាឯកទេសផ្នែកយេនឌ័រត្រូវបានជ្រើសរើសសម្រាប់គម្រោងនេះ ដើម្បីបញ្ជ្រាបបញ្ហាយេនឌ័រក្នុងវិធីពិនិត្យបញ្ញត្តិកម្ម (មើលតារាង២ ផ្នែក៧.១.)។ សារៈសំខាន់របស់ទីប្រឹក្សាឯកទេសផ្នែកយេនឌ័រគឺ៖

១-លើកកម្ពស់ការយល់ដឹងពីបញ្ហាយេនឌ័រក្នុងចំណោមមន្ត្រីគម្រោង

២-បណ្តុះបណ្តាលមន្ត្រីគម្រោង ពីរបៀបបញ្ចូលការវាយតម្លៃផលប៉ះពាល់លើយេនឌ័រទៅក្នុង វ.ផ.ល.

៣-បង្កើតនីតិវិធីពិគ្រោះយោបល់ឲ្យបានសមស្រប និងធ្វើសកម្មភាពផ្សព្វផ្សាយ

៤-ចូលរួមចំណែកក្នុងការរៀបចំសៀវភៅណែនាំប្រតិបត្តិធ្វើបញ្ញត្តិកម្មល្អ និងការរៀបចំរបាយការណ៍ប្រចាំឆ្នាំលើកទី១ ស្តីពីលទ្ធផលនៃបញ្ញត្តិកម្ម (ដែលបានលើកបញ្ហាយេនឌ័រ)

ខាងក្រោមនេះ គឺការរៀបរាប់លម្អិតពីសកម្មភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចនូវគោលបំណងខាងលើ។

## ដំណាក់កាលនៃការចាប់ផ្តើម

វគ្គបណ្តុះបណ្តាលចំនួន២ ត្រូវបានរៀបចំឡើងសម្រាប់មន្ត្រីគម្រោង។ វគ្គទី១ គឺផ្តោតលើគោលបំណងនៃការបញ្ជ្រាបយេនឌ័រនៅក្នុងគម្រោង វ.ផ.ល. តម្រូវឲ្យមានលទ្ធផល និងសកម្មភាពដែលត្រូវអនុវត្ត ដើម្បីធ្វើឲ្យសម្រេចលទ្ធផលនោះ។ វគ្គទី២ណែនាំពីទស្សនៈយេនឌ័រ និងការវិភាគយេនឌ័រនៅក្នុង វ.ផ.ល.។

មានកិច្ចប្រជុំមួយចំនួនក្នុងអំឡុងពេលនៃដំណាក់កាលចាប់ផ្តើម ៖

- ប្រជុំជាមួយមន្ត្រីជាស្ត្រីក្នុង IA និង ORIA ដើម្បីស្វែងយល់ពីបញ្ហាយេនឌ័រ
- ប្រជុំជាមួយក្រុមការងារយេនឌ័ររបស់ MoE ដើម្បីពិភាក្សាលើបញ្ហាយេនឌ័រមួយចំនួននៅក្នុងក្រសួង និងពីរបៀបដែលក្រុមការងារយេនឌ័រសហប្រតិបត្តិការជាមួយគម្រោងវ.ផ.ល.
  - ក្រុមការងារយេនឌ័រនឹងទទួលបានរបាយការណ៍ស្តីពីវ.ផ.ល. របស់ក្រសួងបរិស្ថាន និងទទួលបានឱកាសឲ្យផ្តល់យោបល់
  - ក្រុមការងារយេនឌ័រអាចជួបជាមួយនឹង IA នៅពេលត្រូវការ។
- ចូលរួមកិច្ចប្រជុំវេទិកាអង្គការបណ្តាញយេនឌ័រ (NGO Gender Networking Forum)។

បញ្ហាយេនឌ័របានដាក់បញ្ចូលក្នុងឯកសារ វ.ផ.ល. (បញ្ជីត្រួតពិនិត្យ ទម្រង់ និងគោលការណ៍ណែនាំ)។

## ដំណាក់កាលធ្វើសកម្មភាព

- បណ្តុះបណ្តាលការលើកកម្ពស់ការយល់ដឹងពីយេនឌ័រសម្រាប់មន្ត្រីគម្រោង
- បញ្ចូលការវាយតម្លៃផលប៉ះពាល់យេនឌ័រក្នុង វ.ផ.ល.
  - ធ្វើការជាមួយ IA និងបណ្តុះបណ្តាលពួកគេឲ្យចេះពិនិត្យសំណើបញ្ញត្តិកម្មក្នុងផែនការបញ្ញត្តិកម្ម ដើម្បីកំណត់សំណើបញ្ញត្តិកម្មណាដែលប៉ះពាល់ដល់ស្ត្រីច្រើនជាងបុរស
  - ជួយ IA ឲ្យបំពេញលក្ខខណ្ឌទាក់ទងនឹងយេនឌ័រក្នុងការវាយតម្លៃបឋម
  - ប្រសិនបើតម្រូវឲ្យធ្វើ RIS ដាក់បញ្ចូលក្នុងរបាយការណ៍ស្តីពីផលប៉ះពាល់យេនឌ័រដោយកំណត់ថាតើសំណើបញ្ញត្តិកម្មប៉ះពាល់ស្ត្រីដោយរបៀបណា និងកំណត់ជាតួលេខនៃផលប៉ះពាល់នោះ ប្រសិនបើអាចធ្វើទៅបាន
  - បង្កើតយន្តការពិគ្រោះយោបល់ឲ្យបានសមស្រប ហើយរៀបចំនីតិវិធីនិងគោលការណ៍ណែនាំស្តីពីការពិគ្រោះយោបល់

- ព្រាងជំពូកបញ្ជ្រាបយេនឌ័រ ដែលក្នុងនោះរួមមានគោលការណ៍ណែនាំសម្រាប់សៀវភៅណែនាំប្រតិបត្តិធ្វើបញ្ជ្រាបកម្មល្អ
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ជាផ្នែកនៃសកម្មភាពផ្សព្វផ្សាយ (លទ្ធផល៣)។

## ដំណាក់កាលពង្រឹងនិងវាយតម្លៃ

តាមដានសកម្មភាព វ.ផ.ល.និងរបាយការណ៍ស្តីពី វ.ផ.ល. និងដោះស្រាយចំណុចខ្វះខាត។ លើសពីនេះ ជួយផ្នែកវិភាគបន្ទុកចំណាយនិងផលចំណេញ (CBA) ក្នុងការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដោយផ្តល់ព័ត៌មានពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងបញ្ជ្រាបកម្ម។

## ៩. របាយការណ៍ស្តីពីការងាររដ្ឋបាល

ទីប្រឹក្សានឹងរៀបចំរបាយការណ៍មួយចំនួនដូចខាងក្រោម ៖

តារាង៣ : ទិដ្ឋភាពរួមនៃរបាយការណ៍

| ល.រ | របាយការណ៍ | ពេលវេលា |
|---|---|---|
| ១ | របាយការណ៍ស្តីពីការចាប់ផ្តើម | ខែធ្នូ ឆ្នាំ២០១១ |
| ២ | របាយការណ៍រយៈពេល៦ខែដំបូង | ខែមីនា ឆ្នាំ២០១២ |
| ៣ | របាយការណ៍រយៈពេល៦ខែ លើកទី២ | ខែកញ្ញា ឆ្នាំ២០១២ |
| ៤ | របាយការណ៍ស្តីពីវឌ្ឍនភាពឆ្នាំទី១ | ខែធ្នូ ឆ្នាំ២០១២ |
| ៥ | របាយការណ៍ពាក់កណ្តាលអាណត្តិ និងរបាយការណ៍រយៈពេល ៦ខែ លើកទី៣ | ខែមីនា ឆ្នាំ២០១៣ |
|  | សេចក្តីព្រាងនិងរបាយការណ៍ចុងក្រោយ | ខែមករា ឆ្នាំ២០១៤ |

គម្រោងនឹងរៀបចំកិច្ចប្រជុំជាប្រចាំ ៖

- កិច្ចប្រជុំ២សប្តាហ៍ម្តងសម្រាប់មន្ត្រី ORIA ដឹកនាំដោយអ្នកគ្រប់គ្រងគម្រោង
- កិច្ចប្រជុំប្រចាំខែសម្រាប់មន្ត្រីគម្រោង ដឹកនាំដោយនាយកគម្រោងនៅទីស្តីការគណៈរដ្ឋមន្ត្រី ផ្នែកនីមួយៗរបស់ ORIA និង IA នឹងបង្ហាញពីរបាយការណ៍ស្តីពីវឌ្ឍនភាព ដែលបញ្ចូលទៅក្នុងបណ្តាញទិន្នន័យផ្ទៃក្នុង។ ទម្រង់របាយការណ៍នឹងត្រូវបានរៀបចំឡើង
- កិច្ចប្រជុំពីរដងក្នុងមួយឆ្នាំរបស់គណៈកម្មាធិការនាយករបស់គម្រោង។

# ១០. ដំណើរឆ្ពោះទៅមុខ

## ១០.១. កត្តាកន្លឹះសម្រាប់ភាពជោគជ័យ

McKinsey's 7s រៀបរាប់ពីកត្តាគន្លឹះ ដើម្បីទទួលបានជោគជ័យ។ មន្ត្រីគម្រោងត្រូវផ្តោតលើ វ.ផ.ល. និងចូលរួមបំពេញការងារឲ្យបានពេញម៉ោង។ វាមានសារៈសំខាន់សម្រាប់មន្ត្រីគម្រោងទាំងអស់ធ្វើការរួមគ្នា និងរៀបចំគុណតម្លៃរួមគ្នា។

រូបភាព៨: គោលការណ៍ទាំង៧នៃទ្រឹស្តី McKinsey សម្រាប់អនុវត្តគម្រោង




ប្រភព: ក្របខណ្ឌ McKinsey អនុវត្តចំពោះ ORIA

ដើម្បីទទួលបានជោគជ័យ វ.ផ.ល.គួរបន្ថែមតម្លៃទៅលើវិធីនៃការធ្វើគោលនយោបាយ។ ហេតុនេះមន្ត្រី ORIA គួរយល់ដឹងពីបញ្ហាបច្ចុប្បន្ន ក្នុងផ្នែកដែលខ្លួនទទួលខុសត្រូវ និងផ្តល់យោបល់ដែលនឹងត្រូវបានវាយតម្លៃ។ ចំពោះចំណុចនេះ វាមានសារៈសំខាន់ណាស់នឹងរក្សាវិធីឲ្យសាមញ្ញដោយផ្តោតលើការពិគ្រោះយោបល់ តម្លាភាព និងការវិភាគប្រកបដោយសុភនិច្ឆ័យ។

ការងារបច្ចុប្បន្នរបស់ IA បានផ្តល់វិសាលភាពដ៏ធំធេងសម្រាប់តម្លៃបន្ថែម។ ឧស្សាហកម្មទេសចរណ៍ជាឧស្សាហកម្មដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សនៅកម្ពុជា ហើយមានការវិនិយោគថ្មីជិតពាក់កណ្តាលក្នុងវិស័យនេះ។ ឧស្សាហកម្មកាត់ដេរ ដែលជាវិស័យធំនៅក្នុងប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រងដោយ MIME និង MoC។ MoE ពាក់ព័ន្ធនឹងវិធានការសំខាន់ៗជាច្រើន ដូចជាការអភិវឌ្ឍប្រកបដោយចីរភាព ការប្រែប្រួលអាកាសធាតុ និងគោលនយោបាយបណ្តាញខ្សែបញ្ជូនអគ្គិសនី។ សកម្មភាពទូលំទូលាយទាំងនេះផ្តល់ឱកាសដ៏មានតម្លៃដល់ ORIA ដើម្បីទទួលបានការគោរពពី IA និងជំនឿទុកចិត្ត។

## ១០.២. ការគាំទ្រផ្លូវច្បាប់

អត្ថប្រយោជន៍ចម្បងនៃការគាំទ្រផ្លូវច្បាប់ គឺបង្កើតឲ្យមានភាពច្បាស់លាស់ និងនិរន្តរភាព។ ក្នុងប្រទេសកម្ពុជាដែលប្រព័ន្ធ វ.ផ.ល. ត្រូវបានបង្កើតឡើង ការគាំទ្រផ្លូវច្បាប់អាចជាអត្ថប្រយោជន៍ដ៏សំខាន់មួយ។ ហេតុនេះអនុក្រឹត្យ ដែលមានចំណុចដូចខាងក្រោម អាចមានប្រសិទ្ធភាព ៖

- ធានាឯករាជ្យភាពរបស់ ORIA ក្នុងការវាយតម្លៃលើផលប៉ះពាល់បញ្ញត្តិកម្ម
- ធ្វើឲ្យរបាយការណ៍របស់ ORIA ជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈប្រធាន ECOSOCC មានលក្ខណផ្លូវការ
- តម្រូវឲ្យបង្ហោះរាល់សំណើបញ្ញត្តិកម្មទាំងអស់នៅលើគេហទំព័រ និង
- តម្រូវឲ្យធ្វើការវាយតម្លៃលើផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មទាំងអស់។

បច្ចុប្បន្នក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំពុងធ្វើការងារ ដើម្បីលើកកម្ពស់ដំណើរការតាក់តែងច្បាប់នៅប្រទេសកម្ពុជា។ ដូច្នេះវាអាចជាឱកាសមួយ ដើម្បីដាក់បញ្ចូល វ.ផ.ល.ជាផ្នែកមួយក្នុងវិធីនៃការតាក់តែងច្បាប់។

ការគាំទ្រផ្លូវច្បាប់ចំពោះ វ.ផ.ល. មានលក្ខណៈខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ ដូចជារចនាសម្ព័ន្ធ និងនីតិវិធីអភិបាលកិច្ច។ ដំណើរការ វ.ផ.ល. របស់រដ្ឋាភិបាលអូស្ត្រាលីគឺកំណត់តាមរយៈប្រកាស រដ្ឋាភិបាល (សេចក្តីសម្រេចរបស់ខុទ្ទកាល័យមិនកំណត់ក្នុងច្បាប់ទេ)។ ក្នុងរដ្ឋ Victoria នៃប្រទេសអូស្ត្រាលី លក្ខខណ្ឌតម្រូវ វ.ផ.ល. ត្រូវបានកំណត់ក្នុងច្បាប់។

ក្នុងប្រទេសវៀតណាម វ.ផ.ល. ត្រូវបានកំណត់ដោយច្បាប់ស្តីពីការតាក់តែងច្បាប់ ក្រឹត្យលេខ ២៤/២០០៩/ND-CP។ អនុលោមតាមក្រឹត្យនេះ វ.ផ.ល. ត្រូវតែអនុវត្តចំពោះ ៖

- សំណើបញ្ញត្តិកម្ម ដែលបានដាក់បញ្ចូលក្នុងកម្មវិធីនីតិកម្មប្រចាំឆ្នាំ ដែលធ្វើឡើងដោយរដ្ឋសភា ឬរដ្ឋាភិបាល
- រាល់លិខិតូបករណ៍នីតិកម្មទាំងអស់ ដែលចេញដោយរដ្ឋសភានិងរដ្ឋាភិបាល ដូចជាច្បាប់ សេចក្តីសម្រេចចិត្ត បទបញ្ជា និងក្រឹត្យ

- វ.ផ.ល.ក៏តម្រូវឲ្យផ្សព្វផ្សាយរួមគ្នាជាមួយសេចក្តីព្រាងច្បាប់ផងដែរ ក្នុងរយៈពេលយ៉ាងតិច ៦០ថ្ងៃនៅលើគេហទំព័ររបស់រដ្ឋាភិបាល ឬរបស់ក្រសួង ដើម្បីឲ្យសាធារណជនផ្តល់មតិយោបល់។

## ១០.៣. ការពង្រីក

មានផ្នែកចំនួន៣ ដែល វ.ផ.ល. អាចពង្រីកបាន ៖

- ការពង្រីកងាយស្រួលបំផុតគឺការពង្រីកការអនុវត្ត វ.ផ.ល. ទៅក្រសួងសាកល្បងដទៃទៀត ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងចុងក្រោយគឺរាជរដ្ឋាភិបាលទាំងមូល
- ការពង្រីកការអនុវត្ត វ.ផ.ល. លើលិខិតបទដ្ឋានគតិយុត្តជាធរមានដែលមានស្រាប់ ដែលនាំទៅរកការកាត់បន្ថយបន្ទុកបញ្ញត្តិកម្ម។ ពោលគឺវាយតម្លៃរាល់លិខិតបទដ្ឋានគតិយុត្តជាធរមានដែលមានស្រាប់ទាំងអស់ ក្នុងគោលបំណងលុបចោលលិខិតបទដ្ឋានគតិយុត្តណាដែលមិនផ្តល់ផលចំណេញ (ពោលគឺ វិធីនេះអនុវត្តលើតែលិខិតបទដ្ឋានគតិយុត្តជាធរមានដែលមានស្រាប់)។ ទោះបីជាយ៉ាងណាក៏ដោយ ការវាយតម្លៃបែបនេះគួរអនុវត្តនៅពេលក្រោយ ដោយរង់ចាំការវាយតម្លៃលើផលប៉ះពាល់នៃបញ្ញត្តិកម្មថ្មីឲ្យបានរឹងមាំសិន
- ការពង្រីកវិសាលភាពនៃ វ.ផ.ល. លើសំណើបញ្ញត្តិកម្មទាំងអស់ ជាជាងផ្តោតលើតែបញ្ញត្តិកម្មដែលមានផលប៉ះពាល់ដល់ធុរកិច្ច។

## ១០.៤. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃហានិភ័យ

### ហានិភ័យ

ហានិភ័យចម្បងចំពោះគម្រោងទាក់ទងនឹងការបន្តការប្តេជ្ញាចិត្ត និងការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា។ គម្រោងត្រូវការការគាំទ្រពេញលេញពីរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងទាំង៤។

- មន្ត្រីគម្រោងដែលមានមក ជាពិសេសមន្ត្រីជាន់ខ្ពស់ ដែលមានតួនាទីផ្សេងទៀត ត្រូវតែមានលទ្ធភាពចំណាយពេលវេលានិងខិតខំប្រឹងប្រែងយ៉ាងពេញទំហឹងក្នុងការងារអនុវត្តគម្រោងនេះ
- វាមានសារៈសំខាន់សម្រាប់ វ.ផ.ល. គឺត្រូវបន្ត និងពង្រីកបន្ទាប់ពីចប់គម្រោង។ ភាពមិនច្បាស់លាស់ត្រង់ចំណុចនេះ នឹងមិនលើកទឹកចិត្តមន្ត្រីឲ្យបំពេញការងារ ហើយប៉ះពាល់ដល់ការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការអនុវត្តគម្រោងទៀតផង។

## ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ADB កំពុងរៀបចំដំណើរការប្រើប្រាស់អ្នកឯកទេសខាងតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីរៀបចំក្របខណ្ឌ វ.ផ.ល. និងមូលដ្ឋានសម្រាប់វាយតម្លៃគម្រោងនេះ។ ព័ត៌មានបន្ថែមទាក់ទងនឹងចំណុចនេះ នឹងដាក់បញ្ចូលក្នុងរបាយការណ៍រយៈពេល៦ខែដំបូង បន្ទាប់ពីដំណើរការនៃទីប្រឹក្សា។

ឧបត្ថម្ភដោយ

ADB

ធនាគារអភិវឌ្ឍន៍អាស៊ី